ក្រសួងអប់រំ យុវជន និងកីឡា
Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ
National Institute of Education

# និក្ខេបបទ

# ការសិក្សាស្វែងយល់ការរៀបចំ និងការវាយតម្លៃ ផែនការយុទ្ធសាស្រ្តវិស័យអប់រំ ២០១៩-២០២៣ ថ្នាក់រាជធានី ខេត្ត

## INQUIRY ABOUT FORMULATION AND EVALUATION ON PROVINCIAL-EDUCATION STRATEGIC PLAN 2019-2023

**លោក សីន់ កុសល**

**SORN KOSAL**

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ
ជំនាន់ទី៨
ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៩-២០២១

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport


វិទ្យាស្ថានជាតិអប់រំ

National Institute of Education


**និក្ខេបបទ**

# ការសិក្សាស្វែងយល់ការរៀបចំ និងការវាយតម្លៃ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ថ្នាក់រាជធានី ខេត្ត

# INQUIRY ABOUT FORMULATION AND EVALUATION ON PROVINCIAL-EDUCATION STRATEGIC PLAN 2019-2023


**លោក សឺន កុសល**

**SORN KOSAL**


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ

ជំនាន់ទី៨

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៩-២០២១

**សាស្ត្រាចារ្យដឹកនាំ៖ លោក ថៃ ហេង**

**សាស្ត្រាចារ្យដឹកនាំរង៖ បណ្ឌិត ម៉ម ចាន់សៀន**

# សេចក្តីអះអាងរបស់បេក្ខជន

ខ្ញុំបាទឈ្មោះ **ស៊ិន់ កុសល**

សូមបញ្ជាក់ថានិក្ខេបបទស្រាវជ្រាវ «**ការសិក្សាស្វែងយល់ការរៀបចំ និងការវាយតម្លៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ថ្នាក់រាជធានី ខេត្ត**» (INQUIRY ABOUT FORMULATION AND EVALUATION ON PROVINCIAL-EDUCATION STRATEGIC PLAN 2019-2023) សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ នៃវិទ្យាស្ថានជាតិអប់រំ គឺជាស្នាដៃរបស់ខ្ញុំបាទពិតប្រាកដមែន។ ប្រធានបទនេះ ពុំទាន់បានលើកយកមកធ្វើការសិក្សាស្រាវជ្រាវ ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅតាមបណ្តាសាកលវិទ្យាល័យ និងវិទ្យាស្ថាន ឬវិទ្យាស្ថានមានតម្លៃស្មើណាមួយនៅឡើយទេ។ ចំពោះ សេចក្តីដកស្រង់ ឬខ្លឹមសារណាមួយដែលបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ត្រូវបានអនុញ្ញាតពីអ្នក និពន្ធ ឬចុះបញ្ជីឯកសារយោង។ ខ្ញុំសូមធានាអះអាងថា និក្ខេបបទស្រាវជ្រាវនេះ ពិតជាការស្រាវជ្រាវរបស់ខ្ញុំបាទពិតប្រាកដមែន។

ថ្ងៃអង្គារ ១១រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១

ហត្ថលេខាបេក្ខជន

**ស៊ិន់ កុសល**

# លិខិតបញ្ជាក់

**លោក ថៃ ហេង** ជាសាស្ត្រាចារ្យដឹកនាំ

**បណ្ឌិត ម៉ម ចាន់សៀន** ជាសាស្ត្រាចារ្យដឹកនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោក **ស៊ីន់ កុសល** ជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ «**ការសិក្សាស្វែងយល់ការរៀបចំ និងការវាយតម្លៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ថ្នាក់រាជធានី ខេត្ត**» ពិតប្រាកដមែន។

ថ្ងៃអង្គារ ១១រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១

| | |
|---|---|
| **សាស្ត្រាចារ្យដឹកនាំ** | **សាស្ត្រាចារ្យដឹកនាំរង** |
| .............................. | ................................. |
| **លោក ថៃ ហេង** | **បណ្ឌិត ម៉ម ចាន់សៀន** |
| នាយករងវិទ្យាស្ថានជាតិអប់រំ | អនុប្រធានដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការ |

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការពារនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៣៧០៥ អយក. [illegible]

(ការសម្ងាត់)

**លិខិតឧទ្ទេសនាម**

យោង ៖ -លិខិតលេខ១៤៣៤ អយក.ឧទន ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១។
-បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ និងទី៩ ឆ្នាំសិក្សា២០២០-២០២១ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២១។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៨ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១៤-១៥ ខែវិច្ឆិកា ឆ្នាំ២០២១ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តមបណ្ឌិត | ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តមបណ្ឌិត | ឌី ខាំបូលី | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៤-លោកបណ្ឌិត | ឈូក ច័ន្ទឆាយា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោកបណ្ឌិត | នួវ វីរ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោកបណ្ឌិត | សំអោ អង្គារតន៍ | អគ្គ.គផក | សមាជិក |
| ១១-ឯកឧត្តមបណ្ឌិត | ម៉ុក សារ៉ុម | អគ្គ.អប់រំ | សមាជិក |
| ១២-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកបណ្ឌិត | នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤-លោក | ម៉ៅ សារឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥-លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៦-លោក | លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៧-លោកបណ្ឌិត | ម៉ម ចាន់សៀន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៨-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៩-លោកបណ្ឌិត | អាន វ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០-លោកបណ្ឌិត | កាង ស៊ុងឆាង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១-លោក | ប៉ូ ប៊ុន្នន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

| | | | |
|---|---|---|---|
| ២២-លោកស្រី | ខែក សំណាង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣-លោក | សៀង វាសនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤-លោកស្រី | នូ ចន្ធី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៥-លោក | ឡុច ចាន់ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៦-លោក | លន លីណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៧-លោក | ចាន់ ធឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៩-ល.ស | សុខ វណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៨-លោក | ជាង ចាន់ណាក់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៣០-លោក | អ៊ុច ផលរដ្ឋ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតពីថ្ងៃទី១៤-១៥ ខែវិច្ឆិកា ឆ្នាំ២០២១ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។/

ថ្ងៃ ពុធ ៦កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី

"ដើម្បីជ្រាបជាព័ត៌មាន"

-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ

"ដើម្បីជ្រាបជាព័ត៌មាន"

-សាមីខ្លួន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ -ឯកសារ រដែអ

# សេចក្តីថ្លែងអំណរគុណ

ជាបឋម ខ្ញុំបាទសូមថ្លែងអំណរគុណដល់វិទ្យាស្ថានជាតិអប់រំនៃក្រសួងអប់រំ យុវជន និងកីឡា ដែលបានបង្កើតកម្មវិធីថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំសម្រាប់បុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ឱ្យមានឱកាសបន្តការសិក្សា ដើម្បីបង្កើនគុណវុឌ្ឍិបន្ថែម ក៏ដូចជាផ្តល់ឱកាសដល់រូបខ្ញុំបាទបានចូលសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នេះ ដើម្បីបង្កើនសមត្ថភាពជួយដល់វិស័យអប់រំនៅកម្ពុជា។

ខ្ញុំបាទសូមរំលឹកគុណចំពោះអ្នកមានគុណទាំងពីរ លោកឪពុកអ្នកម្តាយ ព្រមទាំង ភរិយា និងបងប្អូនទាំងអស់ដែលជានិច្ចកាលបានផ្តល់កម្លាំងចិត្ត ពេលវេលា ថវិកា និងការគាំទ្រនានាដល់រូបខ្ញុំគ្រប់ពេលវេលា ជាពិសេសក្នុងការសិក្សារៀនសូត្រក្រេបយកចំណេះដឹងជួយដល់គ្រួសារ និងសង្គមជាតិ។ ជាការពិតណាស់ការជួយឧបត្ថម្ភគាំទ្រ និងការលះបង់របស់អ្នកទាំងអស់គ្នាពិតជាមានតម្លៃមិនអាចកាត់ថ្លៃបានក្នុងការជំរុញឱ្យខ្ញុំខិតខំសិក្សារហូតដល់ទទួលបានជោគជ័យ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះសាស្ត្រាចារ្យទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ និងខិតខំបង្ហាត់បង្រៀន និងពន្យល់មេរៀនដល់រូបខ្ញុំ ដោយមិនគិតពីការនឿយហត់។ ជាមួយគ្នានេះដែរ ខ្ញុំសូមអរគុណចំពោះសាស្ត្រាចារ្យដឹកនាំ **លោក ថៃ ហេង** និងសាស្ត្រាចារ្យដឹកនាំរង **លោកបណ្ឌិត ម៉ម ចាន់សៀន** ដែលបានចំណាយពេលវេលាដ៏មមាញឹក ណែនាំ និងពន្យល់ពីការសរសេរនិក្ខេបបទតាំងពីដើមរហូតដល់ចប់ប្រកបដោយជោគជ័យ។

ខ្ញុំសូមអរគុណដល់មិត្តរួមថ្នាក់ និងរួមជំនាន់ទាំងអស់ដែលបានរាប់អានខ្ញុំ និងបានរួមសុខទុក្ខជាមួយគ្នាទាំងក្នុងការសិក្សា និងក្រៅការសិក្សានាពេលកន្លងមក។ ពេលវេលាដ៏វិសេសវិសាលនេះ បានដក់ជាប់ក្នុងចិត្តរបស់ខ្ញុំជារៀងរហូត។

ជាទីបញ្ចប់ ខ្ញុំបាទ សូមប្រសិទ្ធពរជ័យជូនចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី លោកគ្រូ អ្នកគ្រូ និងញាតិមិត្តទាំងអស់ សូម ឱ្យមានសុខភាពល្អបរិបូរណ៍ កម្លាំងពលំមាំមួន និងជោគជ័យគ្រប់ភារកិច្ចទាំងអស់ ព្រមទាំងទទួលបាននូវពុទ្ធពរ៤ប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមគោរពថ្លែងអំណរគុណ និងសូមអរគុណ!

# មូលន័យសង្ខេប

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់រាជធានី ខេត្ត ដែលបានរៀបចំប្រកបដោយគុណភាពពិតជាមានសារៈសំខាន់សម្រាប់អភិវឌ្ឍន៍វិស័យអប់រំ។ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត បានរៀបចំផែនយុទ្ធសាស្ត្រវិស័យអប់រំនេះ ចាប់តាំងពីឆ្នាំ២០០៦ រហូតដល់បច្ចុប្បន្ននេះ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត បានរៀបចំផែនយុទ្ធសាស្ត្រវិស័យអប់រំ បាន៣លើករួចមកហើយ។ ទោះបីជា រាជធានី ខេត្ត មានបទពិសោធក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំក៏ដោយ ក៏បញ្ហាប្រឈមនៅតែមានសម្រាប់រាជធានី ខេត្ត ទាំងការរៀបចំ និងគុណភាពនៃផែនការ ដូច្នេះបានជាត្រូវសិក្សាស្វែងយល់ពីការរៀបចំ និងការវាយតម្លៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់រាជធានី ខេត្ត ដើម្បីរកឱ្យឃើញពីវឌ្ឍនភាព បញ្ហាប្រឈម និងការចូលរួមពីអ្នកពាក់ព័ន្ធ ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ប្រកបដោយគុណភាព។ អ្នកសិក្សាស្រាវជ្រាវបានជ្រើសរើសរាជធានី ខេត្ត ចំនួន៩ រួមមាន៖ ខេត្តបន្ទាយមានជ័យ ឧត្តរមានជ័យ រតនគិរី កំពង់ធំ ត្បូងឃ្មុំ តាកែវ រាជធានីភ្នំពេញ កោះកុង និងប៉ៃលិន និងបានកំណត់សមាសភាពគោលដៅសម្រាប់បំពេញកម្រងសំណួរ មានដូចជា៖ ថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡា ការិយាល័យផែនការនិងគ្រប់គ្រងជំនួយ ការិយាល័យពាក់ព័ន្ធផ្សេងទៀត សរុប ៧៧នាក់ ដើម្បីប្រមូលជាតុចូលពាក់ព័ន្ធនឹងការរៀបចំ និងអាចវាយតម្លៃពីគុណភាពនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់រាជធានី ខេត្ត។ ក្នុងនោះការសិក្សាស្រាវជ្រាវធ្វើឡើងតាមបែបបរិមាណវិស័យតាមរយៈការបំពេញកម្រងសំណួរតាម Google Form ដោយប្រមូលទិន្នន័យធ្វើការវិភាគតាមកម្មវិធី Microsoft Excel។ លទ្ធផលនៃការស្រាវជ្រាវនេះ នឹងរួមចំណែកយ៉ាងសំខាន់ក្នុងការជួយដល់រាជធានី ខេត្ត ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំប្រកបដោយគុណភាព ដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ ដើម្បីអភិវឌ្ឍវិស័យអប់រំឱ្យឆ្លើយតបនឹងបរិបទប្រទេស និន្នាការតំបន់ និងពិភពលោក។

# Abstract

The provincial education strategic plan 2019-2023 (PESP) which has been prepared with quality is really important for the development of the education sector. The Provincial of Education Offices (POEs) have prepared education strategic plan since 2006 until now, POEs have prepared education strategic plan three times already. Although POEs have experience in developing education strategic plans, the challenges remain for POEs, both in terms of preparation and quality of the plan, so it is necessary to inquiry about formulation and evaluation on provincial-education strategic plan 2019-2023 to find out the progress, challenges and participation of stakeholders in the preparation of a quality education strategic plan 2019-2023. The researcher selected nine provinces such as Banteay Meanchey, Oddar Meanchey, Ratanakiri, Kampong Thom, Tbong Khmum, Phnom Penh, Koh Kong, Takeo and Pailin and identified the target components to answer the questions such as POE directors or deputy directors who are respond in planning, Planning Office and Relevant Offices in total of 77 to collect inputs related to the preparation and can evaluate the quality of the provincial education strategic plan 2019-2023. The research was conducted quantitatively by completing the Google Form Questionnaire. The collecting data is for analysis by Microsoft Excel. The results of this research will significantly contribute to the POEs in formulating a quality education strategic plan with the participation of all stakeholders to develop the education sector in response to the context of the country, regional and global trends.

# មាតិកា

**សេចក្តីអះអាងរបស់បេក្ខជន** ......... i

**លិខិតបញ្ជាក់** ......... ii

**លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការពារនិក្ខេបបទ** ......... iii

**មូលន័យសង្ខេប** ......... vi

Abstract ......... vii

**បញ្ជីតារាង** ......... viii

**ជំពូក១៖ សេចក្តីផ្តើម** ......... 1

១.១ សារៈតានៃការស្រាវជ្រាវ ......... 1

១.២ លំនាំបញ្ហានៃការស្រាវជ្រាវ ......... 3

១.៣ គោលបំណងនៃការស្រាវជ្រាវ ......... 4

១.៤ សំណួរស្រាវជ្រាវ ......... 4

១.៥ សារៈសំខាន់នៃការស្រាវជ្រាវ ......... 4

១.៦ វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ ......... 4

១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ......... 5

**ជំពូក២៖ រំលឹកទ្រឹស្តី** ......... 6

២.១ សេចក្តីផ្តើម ......... 6

២.២ ដំណើរការរៀបចំផែនការ ......... 7

២.៣ លក្ខណៈផែនការយុទ្ធសាស្ត្រល្អ ......... 9

២.៤ ការពង្រឹងសមត្ថភាពបុគ្គលិកក្នុងការរៀបចំផែនការ ......... 10

**ជំពូក៣៖ វិធីសាស្ត្រស្រាវជ្រាវ** ......... 13

៣.១ គម្រោងវិភាគ ......... 13

៣.២ ការជ្រើសរើសសំណាក ......... 13

៣.៣ ឧបករណ៍ស្រាវជ្រាវ ......... 14

៣.៤ ការប្រមូលទិន្នន័យ ........ 14
៣.៥ ការវិភាគទិន្នន័យ ........ 15
**ជំពូក៤៖ លទ្ធផល និងការពិភាក្សា** ........ 16
៤.១ ព័ត៌មានទូទៅអំពីអ្នកចូលរួម ........ 16
៤.២ ដំណើរការរៀបចំ និងក្របខណ្ឌពេលវេលា ........ 17
៤.២.១ ការទទួលបានព័ត៌មានណែនាំ ........ 17
៤.២.២ ការរៀបចំក្រុមការងារ និងការបំពេញការងារ ........ 18
៤.២.៣ ដំណើរការរៀបចំ ........ 25
៤.៣ វង្វាយតម្លៃផែនការរាជធានីខេត្ត ធៀបនឹងស្តង់ដាផែនការថ្នាក់ជាតិ ........ 27
៤.៤ ការពង្រឹងសមត្ថភាពបុគ្គលិក និងការគាំទ្រ ........ 29
៤.៥ បញ្ហាប្រឈម និងដំណោះស្រាយ ........ 33
៤.៥.១ បញ្ហាប្រឈម ........ 33
៤.៥.២ ដំណោះស្រាយ ........ 34
**ជំពូក៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ** ........ 36
៥.១ សេចក្តីសន្និដ្ឋាន ........ 36
៥.២ សំណូមពរ ........ 37
**ឯកសារយោង** ........ 38
**ឧបសម្ព័ន្ធ** ........ 40
ឧបសម្ព័ន្ធ ១៖ កម្រង់សំណួរស្រាវជ្រាវ ........ 40
ឧបសម្ព័ន្ធ ២៖ លិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងការស្រាវជ្រាវ ........ 59

# បញ្ជីតារាង


| លរ. | បរិយាយ | ទំព័រ |
|---|---|---|
| តារាង៤.១៖ | ព័ត៌មានទូទៅពីអ្នកចូលរួម | 16 |
| តារាង៤.២៖ | សេចក្តីណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្រ្តវិស័យអប់រំ២០១៩-២០២៣ | 17 |
| តារាង៤.៣៖ | ការបង្កើតក្រុមការងារសម្រាប់រៀបចំផែនការយុទ្ធសាស្រ្តវិស័យអប់រំ២០១៩-២០២៣ | 18 |
| តារាង៤.៤៖ | ក្រុមលេខាធិការដ្ឋានសម្របសម្រួលការងាររៀបចំផែនការយុទ្ធសាស្រ្តវិស័យអប់រំ ២០១៩-២០២៣ តាមសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា | 20 |
| តារាង៤.៥៖ | លេខាធិការដ្ឋានបានរៀបចំ និងសម្របសម្រួលការប្រជុំពិគ្រោះយោបល់ជាមួយក្រុមបច្ចេកទេស | 21 |
| តារាង៤.៦៖ | អ្នកពាក់ព័ន្ធទាំងអស់នៅក្នុងក្រុមបច្ចេកទេស និងក្រុមលេខាធិការដ្ឋានបានចូលរួមប្រជុំពិគ្រោះយោបល់ តាមការអញ្ជើញរបស់ថ្នាក់ដឹកនាំមន្ទីរ | 22 |
| តារាង៤.៧៖ | ការិយាល័យផែនការ និងគ្រប់គ្រងជំនួយបានអញ្ជើញការិយាល័យពាក់ព័ន្ធទាំងអស់ចូលរួមប្រជុំពិគ្រោះយោបល់ និងប្រជុំតាមអនុវិស័យ និងរបាយការណ៍ | 22 |
| តារាង៤.៨៖ | ការិយាល័យផែនការនិងគ្រប់គ្រងជំនួយបានប្រជុំពិគ្រោះយោបល់ជាមួយការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ សាលារៀន និងអង្គភាព/ស្ថាប័នពាក់ព័ន្ធ ផ្សេងទៀត | 23 |
| តារាង៤.៩៖ | ការិយាល័យពាក់ព័ន្ធបានចូលរួមប្រជុំពិគ្រោះយោបល់ជាមួយការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសាលារៀន | 24 |
| តារាង៤.១០៖ | ការរៀបចំផែនការយុទ្ធសាស្រ្តវិស័យអប់រំ ២០១៩-២០២៣ បានទាន់ពេលវេលាតាមសេចក្តីណែនាំ | 25 |
| តារាង៤.១១៖ | លំដាប់លំដោយនៃដំណើរការរៀបចំផែនការយុទ្ធសាស្រ្តវិស័យអប់រំ២០១៩-២០២៣ | 25 |
| តារាង៤.១២៖ | លំដាប់លំដោយនៃដំណើរការរៀបចំថវិកានៅក្នុងផែនការយុទ្ធសាស្រ្តវិស័យអប់រំ ២០១៩-២០២៣ | 26 |
| តារាង៤.១៣៖ | ក្រុមបង្គោលតាមអនុវិស័យនីមួយៗបានទទួលការបណ្តុះបណ្តាល និងការណែនាំស្តីពីផែនការអប់រំ | 29 |
| តារាង៤.១៤៖ | នាយកដ្ឋានផែនការបានជួយសម្របសម្រួល និងគាំទ្របច្ចេកទេសដល់ការរៀបចំផែនការយុទ្ធសាស្រ្តវិស័យអប់រំ ២០១៩-២០២៣ | 30 |
| តារាង៤.១៥៖ | ការិយាល័យផែនការ និងគ្រប់គ្រងជំនួយបានជួយគាំទ្របច្ចេកទេសដល់ការរៀបចំផែនការយុទ្ធសាស្រ្តវិស័យអប់រំ ២០១៩-២០២៣ | 31 |
| តារាង៤.១៦៖ | ក្រុមបង្គោលតាមអនុវិស័យនីមួយៗបានទទួលការបណ្តុះបណ្តាល និងការណែនាំស្តីពីផែនការអប់រំ | 31 |
| តារាង៤.១៧៖ | បញ្ហាប្រឈមអ្វីខ្លះក្នុងដំណើរការរៀបចំផែនការយុទ្ធសាស្រ្តវិស័យអប់រំ ២០១៩-២០២៣ | 33 |
| តារាង៤.១៨៖ | ការរៀបចំផែនការយុទ្ធសាស្រ្តវិស័យអប់រំមានប្រសិទ្ធភាព | 34 |

# ជំពូក១៖ សេចក្តីផ្តើម

## ១.១ សាវតានៃការស្រាវជ្រាវ

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ជាផែនទីបង្ហាញផ្លូវសម្រាប់អភិវឌ្ឍន៍វិស័យអប់រំប្រកបដោយគុណភាព ប្រសិទ្ធភាព សមធម៌ បរិយាបន្ន ការសិក្សាពេញមួយជីវិត សម្រាប់ទាំងអស់គ្នា ដើម្បីឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំគឺជាផែនការរយៈពេលមធ្យមដែលមានរយៈពេល៥ឆ្នាំ។ ផែនការនេះ ជាផែនការគោលសម្រាប់រៀបចំផែនការផ្សេងៗទៀតនៅក្នុងវិស័យអប់រំដែលរួមមានផែនការយុទ្ធសាស្ត្រថវិកា (៣ឆ្នាំរំកិល) និងផែនការប្រតិបត្តិប្រចាំឆ្នាំ។ ផ្តើមចេញពីគោលដៅអភិវឌ្ឍប្រកបដោយចីរភាពសកលឆ្នាំ២០៣០ រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំគោលដៅអភិវឌ្ឍប្រកបដោយចីរភាពសម្រាប់កម្ពុជាដែលត្រូវបានអនុម័តដោយទីស្តីការគណរដ្ឋមន្ត្រីនៅឆ្នាំ២០១៨។ គោលដៅមួយក្នុងចំណោមគោលដៅទាំង១៧ មានគោលដៅទី៤ ដែលទាក់ទងនឹងការអប់រំ ដោយបានសង្កត់ធ្ងន់លើការធានាការអប់រំប្រកបដោយគុណភាព បរិយាបន្ន និងសមធម៌ និងលើកកម្ពស់កាលានុវត្តភាពសិក្សាពេញមួយជីវិតសម្រាប់ប្រជាជនគ្រប់រូប (រាជរដ្ឋាភិបាល, ២០១៨)។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ត្រូវបានរៀបចំឡើងដោយយោងតាមគោលដៅអភិវឌ្ឍប្រកបដោយចីរភាព ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ យុទ្ធសាស្ត្រចតុកោណរាជរដ្ឋាភិបាល និងកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល (MoEYS, 2019, p. 1)។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំមានបួនកម្រិតគឺផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់ជាតិ ផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់រាជធានី-ខេត្ត និងផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់ក្រុង ស្រុក ខណ្ឌ និងនៅកម្រិតសាលារៀនមានផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀនរយៈពេល៥ឆ្នាំផងដែរ។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ បានរៀបចំឡើងតាមអនុវិស័យចំនួន៧ សម្រាប់ថ្នាក់ជាតិ ដូចជា អនុវិស័យការអប់រំកុមារតូច អនុវិស័យការអប់រំបឋមសិក្សា អនុវិស័យការអប់រំមធ្យមសិក្សា និងការអប់រំបច្ចេកទេស អនុវិស័យការអប់រំឧត្តមសិក្សា អនុវិស័យការអប់រំក្រៅប្រព័ន្ធ អនុវិស័យការអភិវឌ្ឍយុវជន និងអនុវិស័យការអប់រំកាយ និងកីឡា។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់រាជធានី ខេត្ត ២០១៩-២០២៣ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់ក្រុង ស្រុក

២០១៩-២០២៣ មានតែ៦អនុវិស័យ ដោយមិនមានអនុវិស័យការអប់រំឧត្តមសិក្សា។ ក្រសួងអប់រំ យុវជន និងកីឡា បានចាប់ផ្តើមឱ្យមានការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់ជាតិរយៈពេល៥ឆ្នាំ (២០០១-២០០៥) លើកដំបូង ស្របតាមដំណើរការអភិវឌ្ឍរបស់រាជរដ្ឋាភិបាលក្នុងអាណត្តិទី ៣ នៃសភាជាតិ។ បន្ទាប់មកក្រសួងបានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់ជាតិ ២០០៣-២០០៥ លើកទី២ ដើម្បីអភិវឌ្ឍវិស័យអប់រំឆ្លើយតបនឹងបរិបទសកលលោកសំដៅលើកកម្ពស់ការអប់រំសម្រាប់ទាំងអស់គ្នា និងផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់ជាតិ ២០០៦-២០១០ លើកទី៣។ បន្ទាប់មក ដើម្បីឱ្យស្របតាមអាណត្តិរបស់រាជរដ្ឋាភិបាលការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់ជាតិ លើកទី៤ ២០០៩-២០១៣ និងលើកទី៥ ២០១៤-២០១៨ បន្តរៀងមករហូតដល់បច្ចុប្បន្នផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ (Onn & Hyojin, 2019)។

ក្រសួងអប់រំ យុវជន និងកីឡាបានតម្រូវឱ្យមន្ទីរអប់រំ យុវជន និងកីឡារៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ថ្នាក់រាជធានី ខេត្ត ដើម្បីធានាបាននូវការផ្តល់សេវា និងគុណភាពអប់រំ។ ក្រសួងបានចេញសេចក្តីណែនាំដល់មន្ទីរអប់រំ យុវជន និងកីឡាគ្រប់រាជធានី ខេត្ត ដោយបានលើកទឹកចិត្តឱ្យមន្ទីររៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំលើកដំបូងនៅឆ្នាំ២០០៦ ដែលមានរយៈពេល៣ឆ្នាំ (២០០៧-២០០៩) និងការរៀបចំលើកទី២នៅឆ្នាំ ២០១៤ ដែលមានរយៈពេល៣ឆ្នាំដដែល (២០១៥-២០១៧) ក្រោយមកក្រសួងបានតម្រូវឱ្យមន្ទីររៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់រាជធានី ខេត្ត មានរយៈពេល៥ឆ្នាំវិញ (២០១៩-២០២៣) ដែលបានកំពុងអនុវត្តនៅបច្ចុប្បន្ននេះ។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់រាជធានីខេត្តត្រូវបានរៀបចំឡើងឱ្យមានសង្គតិភាពជាមួយផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់ជាតិ ព្រមទាំងការផ្សារភ្ជាប់ផែនការទៅនឹងថវិកា។ ការរៀបចំផែនការនេះ ត្រូវមានយន្តការការងារច្បាស់លាស់ ការពិភាក្សាពិគ្រោះយោបល់ពីគ្រប់ភាគីពាក់ព័ន្ធ ដើម្បីធានាបាននូវគុណភាពនៃផែនការ។ ក្នុងរយៈពេល៥ឆ្នាំនៃការអនុវត្តផែនការនេះ ត្រូវមានការពិនិត្យតាមដាន និងវាយតម្លៃពាក់កណ្តាលអាណត្តិ ដើម្បីពិនិត្យមើលវឌ្ឍនភាព ប្រសិទ្ធភាព ស័ក្តសិទ្ធិភាព និងបញ្ហាប្រឈម ដែលបានអនុវត្តកន្លងមក ថាតើសូនាករណាមិនទាន់

សម្រេចតាមចំណុចដៅ និងត្រូវអន្តរាគមន៍បែបណា ដើម្បីឱ្យសម្រេចតាមចំណុចដៅនៅពេលវាយតម្លៃបញ្ចប់។

## ១.២ លំនាំបញ្ហានៃការស្រាវជ្រាវ

មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត បានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ បាន៣លើករួចមកហើយចាប់តាំងពីឆ្នាំ២០០៦មក។ ដោយសារផែនការនេះជាផែនការថ្មីសម្រាប់មន្ទីរអប់រំ យុវជន និងកីឡា ធ្វើឱ្យមានបញ្ហាប្រឈមជាច្រើន ដែលពេលនោះមានតែ៣ ខេត្ត ប៉ុណ្ណោះ ដែលបានរៀបចំចប់សព្វគ្រប់ និងបានផ្អាកការរៀបចំផែនការនេះរហូតដល់ក្រសួងបានចេញសេចក្តីណែនាំជាថ្មីនៅឆ្នាំ២០១៤ លើកទឹកចិត្តឱ្យមន្ទីរអប់រំ យុវជន និងកីឡា គ្រប់រាជធានី ខេត្ត រៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៥-២០១៧ លើកទី២ សារជាថ្មី ដែលមានរយៈពេល៣ឆ្នាំដដែល (Onn & Hyojin, 2019)។ ដោយរយៈពេលនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត មិនទាន់មានសង្គតិភាពជាមួយនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់ថ្នាក់ជាតិ ក្រសួងបានតម្រូវឱ្យមន្ទីររៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ដែលមានរយៈពេល៥ឆ្នាំដូចថ្នាក់ជាតិ។ ទោះបីយ៉ាងណា ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់រាជធានី ខេត្ត នៅជួបបញ្ហាប្រឈមមួយចំនួន ដូចជា (១) កង្វះចំណេះដឹងអំពីនីតិវិធីក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ (២) កង្វះការគាំទ្របច្ចេកទេសពីថ្នាក់ជាតិ (៣) សមត្ថភាពរបស់មន្ត្រីផែនការក្នុងការប្រើប្រាស់គំនិត និងស្ថិតិនៅមានកម្រិត (៤) ការចូលរួមពីអ្នកពាក់ព័ន្ធនៅមានកម្រិត (៥) កង្វះមន្ត្រីផែនការ និងពេលវេលាសម្រាប់ការរៀបចំ (៦) ទិន្នន័យខ្លះមិនគួរឱ្យទុកចិត្តបានសម្រាប់ក្រុមជនជាតិដើមភាគតិច និងសមត្ថភាពនៅមានកម្រិតទាបក្នុងការធ្វើហេតុវិនិច្ឆ័យវិស័យអប់រំ (Onn & Hyojin, 2019)។ ហេតុនេះ ការសិក្សាស្វែងយល់ពីការរៀបចំ និងវាយតម្លៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់រាជធានី ខេត្ត នឹងរកឱ្យឃើញពីបញ្ហាប្រឈម និងដំណោះស្រាយសម្រាប់ជួយដល់រាជធានី ខេត្ត ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំជាបន្តបន្ទាប់ឱ្យបានល្អប្រសើរ។

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានគោលបំណង៖

- ពិនិត្យមើលដំណើរការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់រាជធានី ខេត្ត លើវឌ្ឍនភាព បញ្ហាប្រឈម និងការចូលរួមរបស់អ្នកពាក់ព័ន្ធ
- វាយតម្លៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់រាជធានី ខេត្ត។

## ១.៤ សំណួរស្រាវជ្រាវ

ដើម្បីសម្រេចបាននូវវត្ថុបំណងនៃការស្រាវជ្រាវ អ្នកស្រាវជ្រាវបានកំណត់សំណួរស្រាវជ្រាវគន្លឹះពីរដូចខាងក្រោម៖

- តើការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់រាជធានី ខេត្ត ដំណើរការយ៉ាងដូចម្តេច?
- តើផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់រាជធានី ខេត្ត មានគុណភាពកម្រិតណា ដើម្បីលើកកម្ពស់គុណភាពអប់រំ?

## ១.៥ សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះមានសារៈប្រយោជន៍ដល់ក្រសួងអប់រំ យុវជន និងកីឡា បានដឹងពីបញ្ហាផ្សេងៗដែលមន្ទីរអប់រំ យុវជន និងកីឡាជួបប្រទះក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងរកវិធីសាស្ត្រជួយដល់មន្ទីរ ដើម្បីដោះស្រាយបញ្ហាប្រឈម។ ម្យ៉ាងទៀតលទ្ធផលនៃការស្រាវជ្រាវនេះ នឹងអាចជួយគាំទ្រដល់មន្ទីរគ្រប់រាជធានី ខេត្ត ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំប្រកបដោយគុណភាព និងបង្កើនការចូលរួមពីភាគីពាក់ព័ន្ធ ដើម្បីលើកកម្ពស់វិស័យអប់រំនៅកម្ពុជា។

## ១.៦ វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះផ្តោតទៅលើការរៀបចំ និងការវាយតម្លៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់រាជធានី ខេត្ត។ អ្នកស្រាវជ្រាវបានជ្រើសរើសរាជធានី ខេត្ត ចំនួន ៩ មកសិក្សា

មានដូចជា៖ ខេត្តបន្ទាយមានជ័យ ឧត្តរមានជ័យ រតនគិរី កំពង់ធំ ត្បូងឃ្មុំ រាជធានីភ្នំពេញ កោះកុង ព្រះសីហនុ និងប៉ៃលិន ដែលរាជធានី ខេត្ត ទាំងនេះមានទីតាំងភូមិសាស្ត្រ និងស្ថានភាពអប់រំខុសៗគ្នា។ សមាសភាពដែលត្រូវចូលរួមឆ្លើយសំណួរមានថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡា ការិយាល័យផែនការ និងគ្រប់គ្រងជំនួយ និងការិយាល័យពាក់ព័ន្ធ សរុប ៧៧នាក់។ ដោយសារមានបញ្ហាប្រឈមក្នុងដំណាក់កាលនៃការរីករាលដាលជំងឺកូវីដ ១៩ ការប្រមូលទិន្នន័យមានការលំបាកដែលមិនអាចឱ្យអ្នកស្រាវជ្រាវចុះទៅប្រមូលទិន្នន័យដោយផ្ទាល់បាន ដូច្នេះការប្រមូលទិន្នន័យបានធ្វើឡើងតាមរយៈអនឡាញ ដោយអ្នកចូលរួមបានបំពេញកម្រងសំណួរនៅក្នុង Google form។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះចែកជា ៥ជំពូក ដូចខាងក្រោម៖

**ជំពូក១៖ សេចក្តីផ្តើម** ផ្តោតលើ សាវតា លំនាំបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ដែនកំណត់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

**ជំពូក២៖ រំលឹកទ្រឹស្តី** ផ្តោតលើផែនការអប់រំរួមមាន៖ សេចក្តីផ្តើម ដំណើរការរៀបចំផែនការ លក្ខណៈផែនការយុទ្ធសាស្ត្រល្អ និងការពង្រឹងសមត្ថភាពបុគ្គលិកក្នុងការរៀបចំផែនការ។

**ជំពូក៣៖ វិធីសាស្ត្រស្រាវជ្រាវ** វិធីសាស្ត្រក្នុងការប្រមូលទិន្នន័យសំណាក ការកំណត់ទំហំ និងដែនកំណត់នៃសំណាក និងឧបករណ៍វិភាគទិន្នន័យ។

**ជំពូក៤៖ លទ្ធផលនៃការស្រាវជ្រាវ** ការបង្ហាញពីលទ្ធផលវិភាគសំណាក តាមរយៈចម្លើយរបស់អ្នកដែលបានចូលរួមឆ្លើយសំណួរ។

**ជំពូក៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ** ការសំយោគខ្លឹមសារនៃលទ្ធផលស្រាវស្រាវ ដើម្បីធ្វើការសន្និដ្ឋានជារួមក្នុងការកំណត់បាននូវវឌ្ឍនភាព បញ្ហាប្រឈម និងសំណូមពរ ដែលឆ្លើយតបនឹងសំណួរស្រាវជ្រាវដែលបានកំណត់សម្រាប់ការពិភាក្សា និងការពិចារណាសម្រាប់កែលម្អផែនការយុទ្ធសាស្ត្រវិស័យអប់រំឱ្យកាន់តែល្អប្រសើរ។

# ជំពូក២៖ រំលឹកទ្រឹស្តី

## ២.១ សេចក្តីផ្តើម

**ផែនការកម្ម** គឺជាមធ្យោបាយមានលក្ខណៈជាប្រព័ន្ធ ដើម្បីដោះស្រាយបញ្ហានាពេលអនាគត។ មធ្យោបាយមានលក្ខណៈប្រព័ន្ធនេះសំដៅទៅលើការធ្វើកិច្ចការជា ជំហានៗ ដោយគិតគូរហ្មត់ចត់ និងប្រុងប្រយ័ត្នអំពីធនធានមនុស្ស ហិរញ្ញវត្ថុ សម្ភារៈ និងក្របខណ្ឌពេលវេលាឱ្យបានសមស្រប។ ការដោះស្រាយបញ្ហាមួយ គឺធ្វើឱ្យមានការប្រែប្រួល និងមានស្ថានភាពល្អប្រសើរជាងមុន ដែលនឹងអាចកាត់បន្ថយ ឬ លុបបំបាត់នូវឧបសគ្គ ឬ បញ្ហានោះ ជាកត្តារាំងស្ទះនូវការសម្រេចវត្ថុបំណង (នាយកដ្ឋានផែនការ, ២០១៩)។ ផែនការកម្ម គឺជាការត្រៀមសកម្មភាពសំខាន់ៗសម្រាប់ជួយដោះស្រាយបញ្ហាទាំងឡាយដែលកើតមាននៅក្នុងអង្គភាព ឬស្ថាប័ននាពេលអនាគត។ ដូចនេះ ត្រូវធ្វើការពិនិត្យឱ្យបានច្បាស់លាស់តាមជំហានត្រឹមត្រូវនីមួយៗ ដែលត្រូវប្រកាន់យកទៅតាមលំដាប់លំដោយ ការប្រើប្រាស់ព័ត៌មាន និងធនធានដែលមាន ដើម្បីទទួលបានដំណោះស្រាយត្រឹមត្រូវដែលនឹងអាចសម្រេចបាននូវវត្ថុបំណងរបស់ស្ថាប័ននោះ (នាយកដ្ឋានផែនការ, ២០១៩)។ **ផែនការអប់រំ** គឺជាការវិភាគជាប្រព័ន្ធអំពីស្ថានភាពអប់រំ ការរៀបចំ ការជ្រើសរើសយុទ្ធសាស្ត្រ សកម្មភាព និងការរៀបចំផែនការអប់រំ ការរៀបចំយន្តការពិនិត្យតាមដាន និងការវាយតម្លៃ ព្រមទាំងការគ្រោងថវិកា ដើម្បីដំណើរការអនុវត្តសកម្មភាពនានាដែលគ្រោងទុក (នាយកដ្ឋានផែនការ, ២០១៩)។ **ផែនការយុទ្ធសាស្ត្រ** គឺជាឧបករណ៍គ្រប់គ្រង ដើម្បីជួយនិងកែលម្អដល់ការអនុវត្តការងាររបស់អង្គភាព និងជំរុញឱ្យសមាជិកបំពេញការងារសម្រេចតាមគោលដៅដែលបានកំណត់ (នាយកដ្ឋានផែនការ, ២០១៩)។

ផែនការយុទ្ធសាស្ត្រមានដើមកំណើតពីភាសាក្រិច ដែលគេបានរៀបចំឡើង ដើម្បីសម្រេចគោលដៅរយៈពេលវែងនៅក្នុងអំឡុងពេលសង្គ្រាម។ ក្នុងអំឡុងទសវត្សឆ្នាំ១៩៦០ ផែនការយុទ្ធសាស្ត្រត្រូវបានប្រើនៅក្នុងវិស័យពាណិជ្ជកម្ម ដើម្បីគ្រប់គ្រងក្រុមហ៊ុន ហើយផែនការយុទ្ធសាស្ត្រនេះ បានវិវត្តន៍បន្តិចម្តងៗទៅក្នុងវិស័យអប់រំក្នុងអំឡុងចុងទសវត្សឆ្នាំ១៩៧០ និងបានផ្សព្វផ្សាយ និងរៀបចំនៅកម្រិតសាលា

រៀននៅក្នុងប្រទេសជាច្រើននៅចុងទសវត្សឆ្នាំ១៩៨០ (IIEP, 2010, p.7-8)។ ក្រុមហ៊ុនឯកជនមានប្រព័ន្ធរៀបចំផែនការយុទ្ធសាស្ត្រ ដើម្បីសម្រេចគោលបំណងដែលបានកំណត់ ដោយមធ្យោបាយជាយុទ្ធសាស្ត្រ និងនីតិវិធីជាក់លាក់ (Gonzalez Escobar, 2019, p.441)។ ផែនការយុទ្ធសាស្ត្រជួយឱ្យបុគ្គលិកនៅក្នុងអង្គភាពធ្វើការរួមគ្នាឆ្ពោះទៅសម្រេចគោលដៅរួមមួយដែលបានកំណត់ ដោយមានភាពបត់បែន និងទន់ភ្លន់ក្នុងការអនុវត្តទៅតាមបរិបទ។

*"ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ត្រូវបានរៀបចំឡើងក្នុងគោលដៅបន្តអនុវត្តកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា និងបង្កើតមូលដ្ឋានរឹងមាំសម្រាប់ឆ្ពោះទៅឆ្នាំ២០៣០ ព្រមទាំងឆ្លើយតបនឹងចក្ខុវិស័យអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា និងកម្មវិធីកំណែទម្រង់នានារបស់រាជរដ្ឋាភិបាលកម្ពុជា។ ផែនការនេះនៅបន្តរក្សាទម្រង់នៃការគ្រប់គ្រងតាមបែបអនុវិស័យ ដើម្បីបង្ហាញពីទំនាក់ទំនងច្បាស់លាស់រវាងវត្ថុបំណងរបស់អនុវិស័យ ក្របខណ្ឌយុទ្ធសាស្ត្រ សកម្មភាពគោល និងតម្រូវការធនធាន ព្រមទាំងផ្តល់ភាពងាយស្រួលក្នុងការពិនិត្យតាមដាននិងវាយតម្លៃ រួមជាមួយនឹងយន្តការសម្រាប់ផ្តល់ព័ត៌មានត្រឡប់ និងការពិនិត្យឡើងវិញផងដែរ" (ESP 2019-2023)។*

*"តាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ និងយុទ្ធសាស្ត្រកំណែទម្រង់ ដោយរំពឹងថា នៅពេលសិស្ស និស្សិតបានបញ្ចប់ការសិក្សារបស់ខ្លួន ពួកគេនឹងមានចំណេះដឹងស្របតាមស្តង់ដាមួយ ព្រមទាំងអាចប្រកួតប្រជែងនៅលើទីផ្សារការងារក្នុងតំបន់ និងលើសកលលោក និងអាចក្លាយជាកម្លាំងស្នូលសម្រាប់ជំរុញការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចរបស់ប្រទេសជាតិ" (Education Congress 2019-2020)។*

## ២.២ ដំណើរការរៀបចំផែនការ

ការរៀបចំផែនការយុទ្ធសាស្ត្រ ត្រូវបានគេមើលឃើញថា ជាការចាប់ផ្តើមរៀនសូត្ររួមគ្នា ដែលជាដំណើរការនៃការទទួលបានបច្ចេកទេសថ្មី និងវិធីសាស្ត្រនៃការរៀបចំ ដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ និងរបៀបដែលពួកគេចូលរួមក្នុងការរៀបចំផែនការ ដោយផ្តល់ឱកាសសម្រាប់ពួកគេធ្វើជាម្ចាស់ក្នុងការ

កំណត់ចក្ខុវិស័យ បេសកកម្ម យុទ្ធសាស្ត្រ កម្មវិធី និងសកម្មភាព និងកំណត់ពីធនធានសម្រាប់អនុវត្ត ផែនការ (Simon, Isabeau & Marion, 2016)។ វដ្តនៃដំណើរការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ មានធាតុសំខាន់ៗដូចជា៖ (១) ការវិភាគវិស័យអប់រំ (២) ការកំណត់គោលនយោបាយអាទិភាព និង យុទ្ធសាស្ត្រ (៣) ការរៀបចំកម្មវិធី (៤) ការកំណត់ពីតម្រូវការហិរញ្ញវត្ថុ (៥) ការរៀបចំផែនការ សកម្មភាព (៦) ការអនុវត្តផែនការ និង (៧) ការពិនិត្យតាមដាន និងវាយតម្លៃ (IIEP-UNESCO, 2015)។ ការរៀបចំផែនការគួរអនុវត្តទៅតាមជំហាន ឬដំណាក់កាលនីមួយៗនៃការរៀបចំផែនការដែល បានទទួលស្គាល់ និងកំពុងអនុវត្តនៅក្នុងបណ្តាប្រទេសជាច្រើននៅលើសកលលោក។ ជាទូទៅ ផែនការ យុទ្ធសាស្ត្រ មានដំណាក់កាលជាក់លាក់ដែលពាក់ព័ន្ធនឹងសកម្មភាពតាមលំដាប់ជាមូលដ្ឋានចំនួនបួន៖ (១) ការវិភាគស្ថានភាព (២) ការរៀបចំផែនការ (៣) ការអនុវត្តផែនការ និង(៤) ការពិនិត្យតាមដាន និងវាយតម្លៃ។ ពាក់ព័ន្ធនឹងលំដាប់លំដោយខាងលើ ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំមានដូច ជា៖ (១) ការវិភាគប្រព័ន្ធ (២) ការបង្កើតគោលនយោបាយ និង(៣) ការរៀបចំផែនការសកម្មភាព។ ការវិភាគប្រព័ន្ធមានការប្រមូលទិន្នន័យ ការវិភាគមុខងារប្រព័ន្ធអប់រំសំខាន់ៗ (សក្តានុពលផ្ទៃក្នុង) និង ការពិនិត្យមើលបរិបទផ្សេងៗ។ ការរៀបចំផែនការសកម្មភាព គឺជាការប្រែក្លាយគោលនយោបាយទៅជា ការអនុវត្តសកម្មភាព និងមានការទទួលខុសត្រូវ។ ក្នុងន័យនេះ ការរៀបចំផែនការសកម្មភាពរួមមានការ បញ្ជាក់ពីគោលបំណង លទ្ធផលរំពឹងទុក យុទ្ធសាស្ត្រ ការទទួលខុសត្រូវ និងពេលវេលាច្បាស់លាស់ (CHANG, 2008, p. 3-4)។ ការរៀបចំផែនការយុទ្ធសាស្ត្រ ត្រូវមានអ្នកជំនាញផែនការចូលរួមគាំទ្រដូច ជាការវិភាគទិន្នន័យ រួមទាំងការកំណត់សូចនាករ ការធ្វើចំណោល ការបង្កើតកម្មវិធី និងការគណនាពី តម្រូវការថវិកា និងមានភាពពាក់ព័ន្ធក្នុងអង្គភាពទាំងមូល ដើម្បីឱ្យមានភាពជាម្ចាស់ក្នុងការអនុវត្ត ពិសេសត្រូវមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ រួមមានកម្រិតគោលនយោបាយ កម្រិតបច្ចេកទេស ដៃគូ អភិវឌ្ឍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងអង្គភាពពាក់ព័ន្ធផ្សេងទៀត ដើម្បីឱ្យការរៀបចំបានគ្រប់ ជ្រុងជ្រោយ ម្យ៉ាងវិញទៀតការរៀបចំត្រូវមាន លក្ខណៈងាយស្រួលក្នុងការពិនិត្យតាមដាន និងវាយ តម្លៃ (IIEP, 2010, p. 8-12)។ ដើម្បីឱ្យមានគណនេយ្យភាពនៃការប្រើប្រាស់ធានធាន និងការអនុវត្ត

ផែនការ យើងត្រូវមានប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃក្នុងការឆ្លុះបញ្ចាំង វិភាគ និងពិនិត្យមើលពីវឌ្ឍភាព និងបញ្ហាប្រឈម ដែលការពិនិត្យតាមដានអាចធ្វើជាប្រចាំថ្ងៃ ឬប្រចាំខែ ដើម្បីតម្រង់ទិសដៅ និងកែលម្អអ្វីដែលយើងកំពុងអនុវត្ត និងការពិនិត្យតាមដានប្រចាំឆ្នាំ ឬ៣ឆ្នាំ ដែលយើងអាចពិនិត្យមើលពីប្រសិទ្ធភាពនិងការប្រែប្រួលដែលបានកើតឡើង ដើម្បីយើងរៀនពីមេរៀនពិសោធន៍សម្រាប់រៀបចំផែនការនាពេលអនាគត (CHANG, 2008, p. 7) ។

យោងតាមសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីក្របខណ្ឌការងាររៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ រាជធានី ខេត្ត ២០១៩-២០២៣ បានណែនាំឱ្យមន្ទីររៀបចំក្រុមការងារ រៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ដែលមានក្រុមបច្ចេកទេស និងក្រុមលេខាធិការដ្ឋាន ក្នុងនោះក៏បានណែនាំពីទម្រង់ដែលមាន៦ជំពូក មានដូចជា ជំពូកទី១៖ សេចក្តីផ្តើម និងការវិភាគការបំពេញការងារ ជំពូក២៖ អាទិភាពនៃការអភិវឌ្ឍរាជធានី ខេត្ត និងគោលនយោបាយអប់រំ ២០១៩-២០២៣ និងចក្ខុវិស័យឆ្នាំ២០៣០ ស្តីពីការអប់រំនៅកម្ពុជា ជំពូក៣៖ ផែនការតាមអនុវិស័យឆ្នាំ ២០១៩-២០២៣ ជំពូក៤៖ ការគ្រប់គ្រង និងការអភិវឌ្ឍសមត្ថភាពនៅរាជធានី ខេត្ត ជំពូក៥៖ ផែនការហិរញ្ញប្បទាន ២០១៩-២០២៣ និងជំពូក៦៖ ការពិនិត្យតាមដាន និងវាយតម្លៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ រាជធានី ខេត្ត (នាយកដ្ឋានផែនការ, ២០១៨)។

## ២.៣ លក្ខណៈផែនការយុទ្ធសាស្ត្រល្អ

ផែនការដែលមានគុណភាព គឺជាតម្រូវការមូលដ្ឋាននៃដំណើរការមួយត្រឹមត្រូវ និងការគ្រប់គ្រងប្រកបដោយគុណភាព និងប្រសិទ្ធភាពនៅក្នុងស្ថាប័ន ឬអង្គភាព។ លក្ខខណ្ឌសម្រាប់ការធ្វើផែនការប្រកបដោយគុណភាព និងប្រសិទ្ធភាពគឺជាការបន្តដំណើរការនៃការវាយតម្លៃ ក្នុងគោលបំណងកាត់បន្ថយ ឬលុបបំបាត់ទាំងស្រុងនូវបញ្ហាប្រឈម តាមរយៈការកែលម្អជាបន្តបន្ទាប់។ ក្នុងដំណើរការ ចាំបាច់ត្រូវធ្វើការវិភាគជាមុន ដើម្បីកំណត់ពីបញ្ហាប្រឈមសំខាន់ៗ។ ការវិភាគអនុវត្តតាមទិដ្ឋភាពដូចតទៅ៖ (១)កំណត់គោលបំណង និងកិច្ចការដែលត្រូវអនុវត្ត (២) រៀបចំសេចក្តីណែនាំ (៣) កំណត់ពីរបៀប

ធ្វើផែនការ និងអ្នកទទួលខុសត្រូវ (៤) វិភាគពីធនធានសម្រាប់ការអនុវត្ត (៥) រៀបចំផែនការលម្អិតពីនីតិវិធីក្នុងការអនុវត្តផែនការ (៦) រៀបចំកាលវិភាគការងារ (៧) កំណត់ពីផលប៉ះពាល់ដែលរំពឹងទុក (Misztal, 2013)។

*"ការរៀបចំផែនការត្រូវមានទំនាក់ទំនងគ្នារវាងផ្នែកវត្ថុបំណង និងផ្នែកសកម្មភាព៖*




*ផ្នែកវត្ថុបំណងរួមមាន៖ **គោលនយោបាយ** គឺជាការសម្រេចចិត្តជាក់លាក់ ឬច្បាស់លាស់ ជាបុគ្គល ឬជាក្រុម ដែលអាចកំណត់ចេញជាបទបញ្ញា ដើម្បីសម្រេចបានទិសដៅនាពេលអនាគត។ **គោលដៅ** ជាលទ្ធផលដែលចង់បានក្នុងរយៈពេលវែង។ **វត្ថុបំណង** ជាលទ្ធផលលម្អិត ជាក់លាក់ដែលទាញចេញពីគោលដៅក្នុងរយៈពេលកំណត់មួយ។ **ចំណុចដៅ** ជាលទ្ធផលគ្រោងទុក ជាក់លាក់ និងអាចវាស់វែងបានក្នុងក្របខណ្ឌពេលវេលារបស់ផែនការ។*

*ផ្នែកសកម្មភាពរួមមាន៖ **យុទ្ធសាស្ត្រ** យុទ្ធវិធីក្នុងការដោះស្រាយបញ្ហា ដើម្បីសម្រេចចំណុចដៅ។ **កម្មវិធី** ជាសំណុំសកម្មភាពទាក់ទងគ្នា (សកម្មភាពគោល) ដែលត្រូវអនុវត្ត ដើម្បីសម្រេចយុទ្ធសាស្ត្រ។ **សកម្មភាព** កិច្ចការដែលត្រូវអនុវត្តក្នុងអំឡុងពេលជាក់លាក់ណាមួយនៃផែនការដើម្បីសម្រេចកម្មវិធី (NIE, ២០១៧)"។*

## ២.៤ ការពង្រឹងសមត្ថភាពបុគ្គលិកក្នុងការរៀបចំផែនការ

ការអភិវឌ្ឍសមត្ថភាពបានក្លាយជាទស្សនទានមួយដ៏ពេញនិយម។ តាមពាក្យបច្ចេកទេសពីមុនគេប្រើ «ការកសាងស្ថាប័ន» ហើយបានប្តូរជា «ការកសាងសមត្ថភាព» បន្ទាប់មកបានប្រើពាក្យថា «ការអភិវឌ្ឍសមត្ថភាព» ប៉ុន្តែការប្រើពាក្យខុសៗគ្នាទាំងនេះ សំដៅលើបញ្ហាប្រឈមស្រដៀងៗគ្នា (Hite &

De Grauwe, 2009, p. 15)។ ការអភិវឌ្ឍសមត្ថភាព គឺជាដំណើរការពង្រឹងសមត្ថភាពបុគ្គល ស្ថាប័ន និងសង្គម ក្នុងការប្រើប្រាស់ធនធានឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ដើម្បីសម្រេចគោលដៅជានិរន្តភាព។ ការអភិវឌ្ឍសមត្ថភាពមានគោលបំណងកែលម្អផ្នែកសំខាន់យ៉ាងហោចណាស់៤៖ (១) ជំនាញ និងការអនុវត្តការងាររបស់បុគ្គល (២) ការអនុវត្តរបស់ស្ថាប័ន (៣) ការងាររដ្ឋបាលសាធារណៈ ដែលបុគ្គលម្នាក់ៗត្រូវបំពេញ ដើម្បីជួយគាំទ្រដល់ស្ថាប័ន និង(៤) បរិបទសង្គម សេដ្ឋកិច្ច និងនយោបាយ ដែលបុគ្គលម្នាក់ៗកំពុងបម្រើការងារ (Hite & De Grauwe, 2009, p. 37)។

សម្រាប់កម្ពុជា ការអភិវឌ្ឍសមត្ថភាពផ្តោតលើ ៣កម្រិត (១) ការអភិវឌ្ឍសមត្ថភាពកម្រិតស្ថាប័ន (២) ការអភិវឌ្ឍសមត្ថភាពកម្រិតអង្គភាព (៣) ការអភិវឌ្ឍសមត្ថភាពបុគ្គល។

*"ការអភិវឌ្ឍសមត្ថភាពមានន័យថា គឺជាលទ្ធភាពធ្វើបានរបស់បុគ្គល ក្រុម និងអង្គភាពក្នុងការបំពេញមុខងារប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងនិរន្តរភាព។ សមត្ថភាពគឺសំដៅទៅលើជំនាញភាពជាអ្នកដឹកនាំ អាចរៀបចំផែនការ អនុវត្ត ពិនិត្យតាមដាននិងវាយតម្លៃ និងកៀរគរធនធាន។ សមត្ថភាពគឺជាលទ្ធភាពធ្វើបានក្នុងការបំពេញការងារ និងផ្តល់សេវាកម្មប្រកបដោយប្រសិទ្ធភាព។ សមត្ថភាពមិនសំដៅទៅលើសមត្ថភាពចាំបាច់ (ចំណេះដឹង និងជំនាញ) ប៉ុណ្ណោះទេ តែក៏សំដៅទៅលើការប្រើប្រាស់ធនធានមនុស្សប្រកបដោយប្រសិទ្ធភាពផងដែរ ពោលគឺជំរុញឱ្យមនុស្សចង់ធ្វើការ និងអាចប្រើប្រាស់សមត្ថភាពដែលខ្លួនមាន។ ក្នុងន័យនេះ ការអភិវឌ្ឍសមត្ថភាពមិនគួរផ្តោតតែទៅលើការកសាងសមត្ថភាពប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវផ្តោតទៅលើការរក្សាទុកធនធានដែលមានសមត្ថភាពនិងប្រើប្រាស់ធនធានទាំងនេះឱ្យបានល្អប្រសើរ ដើម្បីភាពរុងរឿង ចុំចើ្ងរបស់ស្ថាប័នប្រកបដោយនិរន្តរភាព" (CDMP 2020-2024)។*

*"ក្រសួងអប់រំ យុវជន និងកីឡា បាន និងកំពុងអនុវត្តផែនការគោលស្តីពីការអភិវឌ្ឍសមត្ថភាពក្នុងវិស័យអប់រំ ដើម្បីគាំទ្រដល់ការសម្រេចចក្ខុវិស័យ «កសាង និងអភិវឌ្ឍធនធានមនុស្ស ប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជាឱ្យក្លាយជាសង្គមរីកចម្រើន ផ្អែកលើចំណេះដឹង ចំណេះធ្វើជាមូលដ្ឋាន»។ ផែនការគោលស្តីពីការអភិវឌ្ឍសមត្ថភាពក្នុងវិស័យអប់រំ ២០២០-*

២០២៤ ជាផែនទីបង្ហាញផ្លូវ និងជាទិសដៅយុទ្ធសាស្ត្រសម្រាប់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការកសាង និងអភិវឌ្ឍសមត្ថភាពក្នុងវិស័យអប់រំនៅកម្រិតស្ថាប័ន អង្គភាព និងបុគ្គល ដើម្បីបន្តអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ ផែនទីបង្ហាញផ្លូវការអប់រំកម្ពុជាឆ្នាំ២០៣០ និងអាទិភាពកំណែទម្រង់វិស័យអប់រំឱ្យបានជោគជ័យ។ ផែនការគោលនេះ បានកំណត់ ពីក្របខណ្ឌ និងតម្រូវការនៃការអភិវឌ្ឍសមត្ថភាពតាមអនុវិស័យ និងបានកំណត់អាទិភាពសំខាន់ៗចំនួន ៦ ដូចជា កំណែទម្រង់គោលនយោបាយ ផែនការ និងការគ្រប់គ្រងហិរញ្ញវត្ថុ កំណែទម្រង់ការគ្រប់គ្រងធនធានមនុស្ស កំណែទម្រង់ការពិនិត្យតមដាន និងវាយតម្លៃ កំណែទម្រង់ការបណ្តុះបណ្តាលគ្រូបង្រៀន កំណែទម្រង់ការគ្រប់គ្រងតាមសាលារៀន និងការអភិវឌ្ឍកម្មវិធីសិក្សា និងកំណែទម្រង់ការងារអធិការកិច្ច និងវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ព្រមទាំងបានកំណត់យុទ្ធសាស្ត្រ និងសកម្មភាពសំខាន់ៗដើម្បីគាំទ្រសម្រេចនូវកំណែទម្រង់អាទិភាពខាងលើ" (CDMP 2020-2024)។

# ជំពូក៣៖ វិធីសាស្ត្រស្រាវជ្រាវ

## ៣.១ គម្រោងវិភាគ

ការស្រាវជ្រាវនេះរៀបចំឡើងដើម្បីសម្រេចវត្ថុបំណងស្រាវជ្រាវចំនួនពីរគឺ៖ (១) ពិនិត្យមើលដំណើរការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ របស់រាជធានី ខេត្តលើវឌ្ឍនភាព បញ្ហាប្រឈម និងការចូលរួមរបស់អ្នកពាក់ព័ន្ធ និង(២) វាយតម្លៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់រាជធានី ខេត្ត។ ដើម្បីសម្រេចបានវត្ថុបំណងស្រាវជ្រាវទាំងពីរខាងលើ អ្នកស្រាវជ្រាវបានកំណត់យកវិធីសាស្ត្រស្រាវជ្រាវតាមវិធីសាស្ត្របែបបរិមាណវិស័យ ដែលទិន្នន័យបែបបរិមាណវិស័យប្រើប្រាស់ដើម្បីឆ្លើយតបទៅនឹងវត្ថុបំណងទី១ ដោយផ្ដោតលើវឌ្ឍភាព បញ្ហាប្រឈម និងការចូលរួមពីអ្នកពាក់ព័ន្ធក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣។ ដើម្បីសម្រេចវត្ថុបំណងទី២ អ្នកស្រាវជ្រាវបានពិនិត្យផែការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់រាជធានី ខេត្តគោលដៅទាំង៩ធៀបទៅនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ របស់ថ្នាក់ជាតិ គោលការណ៍ណែនាំរបស់នាយកដ្ឋានជំនាញ និងទ្រឹស្ដីនៃការរៀបចំផែនការយុទ្ធសាស្ត្រ។

## ៣.២ ការជ្រើសរើសសំណាក

ដើម្បីឱ្យការសិក្សាស្រាវជ្រាវនេះ ទទួលបានកម្រិតជឿទុកចិត្តខ្ពស់ អ្នកស្រាវជ្រាវបានជ្រើសរើសរាជធានី ខេត្តចំនួន៩ ដោយមិនចៃដន្យ ដោយផ្ដោតលើទីតាំងភូមិសាស្ត្រនៅតំបន់ខ្ពង់រាប វាលទំនាប និងតំបន់សមុទ្រ រួមមានខេត្តធំ មធ្យម និងតូច ដើម្បីឱ្យមានគ្រប់ទិដ្ឋភាព។ រាជធានី ខេត្តទាំងនោះមានដូចជា៖ ខេត្តបន្ទាយមានជ័យ ឧត្តរមានជ័យ រតនគិរី កំពង់ធំ ត្បូងឃ្មុំ រាជធានីភ្នំពេញ កោះកុង ព្រះសីហនុ និងប៉ៃលិន ដែលមានសមាសភាពចូលរួមផ្ដល់ព័ត៌មាន សរុប ៧៧នាក់ មានដូចជា៖ ថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡាទទួលបន្ទុកផែនការ ១នាក់ ក្នុង ១ខេត្ត ប្រធានការិយាល័យផែនការ និងគ្រប់គ្រងជំនួយ ១នាក់ ក្នុង ១ខេត្ត ប្រធានការិយាល័យអប់រំកុមារតូច១នាក់ ក្នុង ១ខេត្ត ប្រធានការិយាល័យបឋមសិក្សា ១នាក់ ក្នុង ១ខេត្ត ប្រធានការិយាល័យមធ្យមសិក្សា១នាក់ ក្នុង ១ខេត្ត ប្រធានការិយាល័យអប់រំក្រៅ

ប្រព័ន្ធ១នាក់ ក្នុង ១ខេត្ត ប្រធានការិយាល័យយុវជន១នាក់ ក្នុង ១ខេត្ត ប្រធានការិយាល័យកីឡា១នាក់ ក្នុង ១ខេត្ត ប្រធានការិយាល័យគណនេយ្យ១នាក់ ក្នុង ១ខេត្ត។

ការជ្រើសរើសសំណាកគំរូយកតែ ៩ រាជធានី ខេត្ត ដោយសារតំណាងសាកលតូច (៩ ក្នុងចំណោម ២៥ ស្មើនឹង ៣៦%) ដូច្នេះ ការជ្រើសរើសសំណាកគំរូ ៩ រាជធានី ខេត្ត អាចតំណាងឱ្យតំណាងសាកលបាន។ ដោយសារមានបញ្ហាប្រឈមក្នុងការប្រមូលទិន្នន័យក្នុងដំណាក់កាលនៃការរីករាលដាលជំងឺកូវីដ ១៩ ការប្រមូលទិន្នន័យពីក្រុមគោលដៅបានតែ ៥១នាក់ ក្នុងនោះមានថ្នាក់ដឹកនាំមន្ទីរ ៩នាក់ ការិយាល័យផែនការ និងគ្រប់គ្រងជំនួយ ៩នាក់ និងការិយាល័យពាក់ព័ន្ធ ៣៣នាក់។ ការបាត់ចំនួនអ្នកចូលរួមបំពេញកម្រងសំណួរនេះ មិនធ្វើឱ្យប៉ះពាល់ដល់ទិន្នន័យសម្រាប់វិភាគនោះទេ។

## ៣.៣ ឧបករណ៍ស្រាវជ្រាវ

ដើម្បីប្រមូលទិន្នន័យឱ្យបានជាក់លាក់ អ្នកស្រាវជ្រាវបានបង្កើតកម្រងសំណួរ៣ប្រភេទៈ ទី១ កម្រងសំណួរសម្រាប់ថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡា ទី២ កម្រងសំណួរសម្រាប់ការិយាល័យផែនការ និងគ្រប់គ្រងជំនួយ និងទី៣ កម្រងសំណួរសម្រាប់ការិយាល័យពាក់ព័ន្ធ រួមមាន ការិយាល័យអប់រំកុមារតូច បឋមសិក្សា មធ្យមសិក្សា អប់រំក្រៅប្រព័ន្ធ យុវជន កីឡា និងគណនេយ្យ។ កម្រងសំណួរទាំងនេះចែកចេញជា៣ផ្នែកៈ ទី១ ព័ត៌មានផ្ទាល់ខ្លួន ទី២ ព័ត៌មានអំពីការរៀបចំផែនការ និងទី៣ យោបល់ និងសំណូមពរផ្សេងៗ។

## ៣.៤ ការប្រមូលទិន្នន័យ

យោងតាមលិខិតលេខ ២៤០៩ អយក.វជអ ចុះថ្ងៃសុក្រ ៧កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់។ បន្ទាប់ពីបានបង្កើតកម្រងសំណួររួចរាល់ ដោយមានការពិនិត្យពីគ្រូដឹកនាំបង្គោល និងគ្រូដឹកនាំរង អ្នកស្រាវជ្រាវបានផ្ញើកម្រងសំណួរជូនរាជធានី ខេត្ត គោលដៅទាំង៩ ដើម្បីបំពេញកម្រងសំណួរតាម Google Form។

## ៣.៥ ការវិភាគទិន្នន័យ

អ្នកស្រាវជ្រាវប្រើប្រាស់កម្មវិធី Microsoft Excel ដើម្បី សង់ក្រាប ធ្វើតារាង និងបកស្រាយ និងវិភាគទិន្នន័យ។

# ជំពូក៤៖ លទ្ធផល និងការពិភាក្សា

ជំពូកនេះអ្នកស្រាវជ្រាវនឹងធ្វើការបង្ហាញ បកស្រាយ និងពិភាក្សាលទ្ធផលនៃការស្រាវជ្រាវដោយប្រើប្រាស់ទិន្នន័យបានមកពីការបំពេញកម្រងសំណួរតាមរយៈ Google form ដែលបានផ្ញើជូនអ្នកចូលរួម ៥១នាក់ នៅមន្ទីរអប់រំ យុវជន និងកីឡា ៩ រាជធានី ខេត្ត ដើម្បីស្វែងយល់ពីវឌ្ឍនភាព បញ្ហាប្រឈម និងការចូលរួមពីអ្នកពាក់ព័ន្ធក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់រាជធានី ខេត្ត និងពិនិត្យមើលផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់រាជធានី ខេត្ត ដើម្បីវាយតម្លៃធៀបនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់ថ្នាក់ជាតិ។

## ៤.១ ព័ត៌មានទូទៅអំពីអ្នកចូលរួម

**តារាង ៤.១៖** ព័ត៌មានទូទៅពីអ្នកចូលរួម (n=៥១)

| ការបរិយាយ | ចំនួន(n) | បទពិសោធក្នុងការងារផែនការ | | |
|---|---|---|---|---|
| មន្ទីរអេ.យ.ក រាជធានី-ខេត្ត | ៩ | តិចជាង៣ឆ្នាំ | ៣-៥ឆ្នាំ | លើសពី៥ឆ្នាំ |
| ប្រធានមន្ទីរអេ.យ.ក | ២ | ០ | ០ | ២ |
| អនុប្រធានមន្ទីរអេ.យ.ក | ៧ | ១ | ១ | ៥ |
| ប្រធានការិយាល័យផែនការ និងគ្រប់គ្រងជំនួយ | ៧ | ២ | ១ | ៤ |
| អនុ.ការិយាល័យផែនការ និងគ្រប់គ្រងជំនួយ | ២ | ០ | ២ | ០ |
| ប្រធានការិយាល័យពាក់ព័ន្ធ | ២១ | ១ | ៥ | ១៥ |
| អនុប្រធានការិយាល័យពាក់ព័ន្ធ | ៩ | ២ | ៤ | ៣ |
| មន្ត្រីការិយាល័យពាក់ព័ន្ធ | ៣ | ១ | ០ | ២ |
| **សរុប** | **៥១** | **៧** (១៣,៧៣%) | **១៣** (២៥,៤៩%) | **៣១** (៦០,៧៨%) |

តារាង៤.១ បង្ហាញថា អ្នកចូលរួមឆ្លើយសំណួរមកពី ៩ រាជធានី ខេត្ត ដែលមានប្រធាន អនុប្រធានមន្ទីរ ប្រធាន អនុប្រធានការិយាល័យផែនការ និងគ្រប់គ្រងជំនួយ ប្រធាន អនុប្រធាន និងមន្ត្រីការិយាល័យពាក់ព័ន្ធភាគច្រើនមានបទពិសោធក្នុងការងារផែនការលើសពី៥ឆ្នាំ មាន ៣១នាក់ (៦០,៧៨%) អ្នក

ដែលមានបទពិសោធពី៣ទៅ៥ឆ្នាំ មាន ១៣នាក់ (២៥,៤៩%) និងអ្នកមានបទពិសោធ៣ឆ្នាំ ឬតិចជាង មានត្រឹមតែ ៧នាក់ (១៣,៧៣%) តែប៉ុណ្ណោះ។ តាមរយៈទិន្នន័យបានបង្ហាញថា ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់រាជធានី ខេត្ត បានរៀបចំឡើងដោយមានអ្នកជំនាញផែនការ និងការិយាល័យពាក់ព័ន្ធដែលមានបទពិសោធការងារផែនការយូរឆ្នាំ។

## ៤.២ ដំណើរការរៀបចំ និងក្របខណ្ឌពេលវេលា

### ៤.២.១ ការទទួលបានព័ត៌មានណែនាំ

**តារាង៤.២៖** សេចក្តីណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣។ (គិតជា%)

| ជម្រើស | ប្រធាន/អនុប្រធានមន្ទីរ (n=៩) | ប្រធាន/អនុប្រធានការិ.ផែនការ (n=៩) | ប្រធាន/អនុប្រធាន/មន្ត្រីការិ.ពាក់ព័ន្ធ (n=៣៣) |
|---|---|---|---|
| បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយរបស់ក្រសួងអប់រំ យុវជន និងកីឡា | ៨៩,៨៩ | ៨៩,៨៩ | ២៤,២៤ |
| បានទទួលតាមរយៈការប្រជុំផ្សព្វផ្សាយពីថ្នាក់ដឹកនាំមន្ទីរ | ០,០០ | ០,០០ | ៣៣,៣៣ |
| បានទទួលតាមរយៈការប្រជុំផ្សព្វផ្សាយពីការិយាល័យផែនការ និងគ្រប់គ្រងជំនួយ | ០,០០ | ០,០០ | ៣៩,៤០ |
| បានទទួលសេចក្តីណែនាំដែលផ្ញើមកពីក្រសួងអប់រំ យុវជន និងកីឡា | ១១,១១ | ១១,១១ | ០,០០ |
| មិនបានទទួលសេចក្តីណែនាំ | ០,០០ | ០,០០ | ៣,០៣ |

ក្រសួងអប់រំ យុវជន និងកីឡា បានចេញសេចក្តីណែនាំ ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ដល់រាជធានី ខេត្ត ដើម្បីណែនាំរាជធានី ខេត្ត រៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ឱ្យមាន សង្គតិភាពនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់ថ្នាក់ជាតិ។ តារាង៤.២ បានបង្ហាញថា ថ្នាក់ដឹកនាំមន្ទីរ និងការិយាល័យផែនការ និងគ្រប់គ្រងជំនួយបានចូលរួមសិក្ខា

សាលាផ្សព្វផ្សាយស្តីពីក្របខណ្ឌការងាររៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ សម្រាប់រាជធានី ខេត្ត ដែលរៀបចំដោយនាយកដ្ឋានផែនការនៃក្រសួងអប់រំ យុវជន និងកីឡា ស្ទើរតែគ្រប់គ្នា (៨៩,៨៩%) ផ្ទុយទៅវិញ ការិយាល័យពាក់ព័ន្ធបានចូលរួមសិក្ខាសាលាផ្សព្វផ្សាយរបស់ក្រសួងអប់រំ យុវជន និងកីឡាបានតិចតួចប៉ុណ្ណោះ (២៤,២៤%) ប៉ុន្តែពួកគាត់បានទទួលតាមរយៈការប្រជុំផ្សព្វផ្សាយពីថ្នាក់ដឹកនាំមន្ទីរ ឬការិយាល័យផែនការ និងគ្រប់គ្រងជំនួយភាគច្រើន (៣៩,៤០%)។ ដូច្នេះ ការផ្សព្វផ្សាយស្តីពីក្របខណ្ឌការងាររៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់ក្រសួងអប់រំ យុវជន និងកីឡា បានទូលំទូលាយដល់អ្នកពាក់ព័ន្ធនៅមន្ទីរដោយផ្ទាល់ និងដោយប្រយោល។

ការទទួលបានការផ្សព្វផ្សាយតាមរយៈការចូលរួមសិក្ខាសាលា ដែលរៀបចំដោយនាយកដ្ឋានជំនាញនៃក្រសួងអប់រំ យុវជន និងកីឡា អាចជានាបាននូវភាពច្បាស់លាស់ទាក់ទងទៅនឹងសេចក្តីណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំជាងតាមវិធីផ្សេងទៀត។ អ្នកចូលរួមរៀបចំផែនការតិចតួចបំផុត (៣.០៣%) ដែលមិនបានទទួលព័ត៌មានស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំនេះ។ តាមរយៈបទពិសោធធ្វើការងារផែនការ និងការទទួលបាននូវសេចក្តីណែនាំអាចឱ្យយើងវាយតម្លៃបានថា ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់គាត់នឹងទទួលបានជោគជ័យ។

### ៤.២.២ ការរៀបចំក្រុមការងារ និងការបំពេញការងារ

**តារាង៤.៣៖** ការបង្កើតក្រុមការងារសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣។ (គិតជា%)

| ជម្រើស | ប្រធាន/អនុប្រធានមន្ទីរ (n=៩) | ប្រធាន/អនុប្រធានការិ.ផែនការ (n=៩) | ប្រធាន/អនុប្រធាន/មន្ត្រីការិ.ពាក់ព័ន្ធ (n=៣៣) |
|---|---|---|---|
| ក្រុមការងារមានសមាសភាពចូលរួមជា ថ្នាក់ដឹកនាំមន្ទីរ ការិយាល័យផែនការនិងគ្រប់គ្រងជំនួយ ការិយាល័យ | ៦៦,៦៧ | ៤៤,៤៤ | ២១,២២ |

| | | | |
|---|---|---|---|
| មួយចំនួន ឬទាំងអស់ និងអង្គភាព ឬស្ថាប័នផ្សេងទៀត | | | |
| ក្រុមការងារមានសមាសភាពចូលរួមជា ថ្នាក់ដឹកនាំមន្ទីរ ការិយាល័យផែនការនិងគ្រប់គ្រងជំនួយនិងការិយាល័យ មួយចំនួន ឬទាំងអស់ | ២២,២២ | ៥៥,៥៦ | ៦៦,៦៦ |
| ក្រុមការងារមានសមាសភាពចូលរួមជា ថ្នាក់ដឹកនាំមន្ទីរ និងការិយាល័យផែនការនិងគ្រប់គ្រងជំនួយ | ១១,១១ | ០,០០ | ៦,០៦ |
| មិនបានបង្កើតក្រុមការងារដោយការិយាល័យផែនការ និងគ្រប់គ្រងជំនួយជាអ្នកសម្របសម្រួលរៀបចំ | ០,០០ | ០,០០ | ៦,០៦ |

តាមសេចក្តីណែនាំរបស់ក្រសួងអប់អប់រំ យុវជន និងកីឡា តម្រូវឱ្យរាជធានី ខេត្តបង្កើតក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ដែលមានក្រុមបច្ចេកទេស និងក្រុមលេខាធិការដ្ឋាន ដោយបានចែងពីតួនាទី និងភារកិច្ចច្បាស់លាស់នៅក្នុងសេចក្តីណែនាំ ក្នុងនោះសមាសភាពនៅក្នុងក្រុមការងារត្រូវមានគ្រប់ភាគីពាក់ព័ន្ធ ដើម្បីឱ្យដំណើរការរៀបចំផែនការបានគ្រប់ជ្រុងជ្រោយ។ តារាង៤.៣ បង្ហាញថា ថ្នាក់ដឹកនាំមន្ទីរភាគច្រើន (៦៦,៦៧%) បានឆ្លើយដូចទៅនឹងសេចក្តីណែនាំរបស់ក្រសួង ដែលក្រុមការងារត្រូវមានសមាសភាពចូលរួមជា ថ្នាក់ដឹកនាំមន្ទីរ ការិយាល័យផែនការនិងគ្រប់គ្រងជំនួយ ការិយាល័យមួយចំនួន និងអង្គភាពផ្សេងទៀត (តំណាងដៃគូអភិវឌ្ឍ) ប៉ុន្តែការឆ្លើយរបស់ថ្នាក់ដឹកនាំមន្ទីរ មិនស៊ីគ្នានឹងចម្លើយរបស់ការិយាល័យជំនាញ និងការរិយាល័យពាក់ព័ន្ធឡើយពីព្រោះមានក្រោម៥០% ដែលឯកភាពទៅតាមចម្លើយនេះ គឺការិយាល័យផែនការ និងគ្រប់គ្រងជំនួយបានឆ្លើយដូចនឹងថ្នាក់ដឹកនាំមន្ទីរ មាន ៤៤,៤៤% និងការិយាល័យពាក់ព័ន្ធមានត្រឹមតែ ២១,២២% តែប៉ុណ្ណោះ។ ផ្ទុយទៅវិញ ការិយាល័យពាក់ព័ន្ធភាគច្រើន(៦៦,៦៦%) និងការិយាល័យផែនការ និងគ្រប់គ្រងជំនួយ (៥៥,៥៦%) បានឆ្លើយថា ក្រុមការងារមានសមាសភាពចូលរួមជា ថ្នាក់ដឹកនាំមន្ទីរ ការិយាល័យផែនការនិងគ្រប់គ្រងជំនួយ និងការិយាល័យមួយចំនួន ឬទាំងអស់។ តាមរយៈចម្លើយនេះ អាចសន្និដ្ឋានបានថា ការរៀបចំក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ថ្នាក់រាជធានី ខេត្តភាគច្រើនមិនមានការ

ចូលរួមពី ដៃគូអភិវឌ្ឍ ឬអង្គភាពផ្សេងទៀត។ សរុបមក ការអនុវត្តរបស់រាជធានី ខេត្ត មានភាពបទបែនទៅតាមរាជធានី ខេត្តនីមួយៗ។

**តារាង៤.៤៖** ក្រុមលេខាធិការដ្ឋានសម្របសម្រួលការងាររៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ តាមសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា។ (គិតជា%)

| ជម្រើស | ប្រធាន/អនុប្រធានមន្ទីរ (n=៩) | ប្រធាន/អនុប្រធានការិ.ផែនការ (n=៩) | ប្រធាន/អនុប្រធាន/មន្ត្រីការិ.ពាក់ព័ន្ធ (n=៣៣) |
|---|---|---|---|
| បានអនុវត្តតាមសេចក្តីណែនាំ | ១០០ | ១០០ | ៩៦,៩៧ |
| មិនបានអនុវត្តតាមសេចក្តីណែនាំ | ០,០០ | ០,០០ | ៣,០៣ |

ក្រោយពីបង្កើតក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ក្រុមលេខាធិការដ្ឋានបានសម្របសម្រួលការងាររៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ តាមតួនាទី និងភារកិច្ច តាមសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ដូចទិន្នន័យក្នុងតារាង៤.៤ បានបង្ហាញថា អ្នកឆ្លើយសំណួរដែលជា ថ្នាក់ដឹកនាំមន្ទីរ និងការិយាល័យផែនការនិងគ្រប់គ្រងជំនួយ (១០០%) បានឆ្លើយថា ក្រុមលេខាធិការដ្ឋានបានសម្របសម្រួលការងាររៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ដោយបានអនុវត្តតាមសេចក្តីណែនាំ និងការិយាល័យពាក់ព័ន្ធ (៩៦,៩៧%) បានឆ្លើយថា ក្រុមលេខាធិការដ្ឋានបានសម្របសម្រួលការងាររៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ ដោយបានអនុវត្តតាមសេចក្តីណែនាំ និងមានតែ ៣,០៣% ប៉ុណ្ណោះ បានឆ្លើយថា លេខាធិការដ្ឋានមិនបានអនុវត្តតាមសេចក្តីណែនាំ។ ដូច្នេះ ក្រុមលេខាធិការដ្ឋានបានខិតខំសម្របសម្រួលជាមួយការិយាល័យផ្សេងៗដើម្បីបានធាតុចូលសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់រាជធានីខេត្ត តាមសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា រហូតបានចប់សព្វគ្រប់។

**តារាង៤.៥៖** លេខាធិការដ្ឋានបានរៀបចំ និងសម្របសម្រួលការប្រជុំពិគ្រោះយោបល់ជាមួយក្រុមបច្ចេកទេស។ (គិតជា%)

| ជម្រើស | ប្រធាន/អនុប្រធានមន្ទីរ (n=៩) | ប្រធាន/អនុប្រធាន ការិ.ផែនការ (n=៩) | ប្រធាន/អនុប្រធាន/ មន្ត្រីការិ.ពាក់ព័ន្ធ (n=៣៣) |
|---|---|---|---|
| ប្រជុំតាមការចាំបាច់ | ១០០ | ១០០ | ៩៣,៩៤ |
| មួយខែមួយដង | ០,០០ | ០,០០ | ៣,០៣ |
| មួយត្រីមាសម្តង | ០,០០ | ០,០០ | ៣,០៣ |

ដំណើរការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ត្រូវមានការប្រជុំពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធឱ្យបានគ្រប់ជ្រុងជ្រោយទើបផែនការនេះធានាបាននូវគុណភាព និងអាចអនុវត្តបាន។ ពាក់ព័ន្ធនឹងចំណុចនេះ អ្នកចូលរួមឆ្លើយសំណួរ ដែលជាថ្នាក់ដឹកនាំមន្ទីរ និងការិយាល័យផែនការនិងគ្រប់គ្រងជំនួយ (១០០%) និងការិយាល័យពាក់ព័ន្ធ (៩៣,៩៤%) បានឆ្លើយថា លេខាធិការដ្ឋានបានរៀបចំ និងសម្របសម្រួលការប្រជុំពិគ្រោះយោបល់ជាមួយក្រុមបច្ចេកទេសតាមការចាំបាច់។ តាមរយៈតារាង៤.៥ បានបង្ហាញថា មន្ទីរអប់រំ យុវជន និងកីឡា មិនបានរៀបចំកាលវិភាគប្រជុំពិគ្រោះយោបល់ជាមួយក្រុមបច្ចេកទេសច្បាស់លាស់នោះទេ វាអាស្រ័យលើពេលវេលា និងតម្រូវការចាំបាច់។ បើយោងតាមសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា បានណែនាំឱ្យមានការប្រជុំតាមអនុវិស័យ ដោយមិនបានបញ្ជាក់ពីការរៀបចំកាលវិភាគប្រជុំពិគ្រោះយោបល់ច្បាស់លាស់ ពីព្រោះទុកលទ្ធភាពឱ្យមន្ទីរអប់រំ យុវជន និងកីឡារៀងៗខ្លួន ធ្វើការសម្រេចទៅតាមស្ថានភាពជាក់ស្តែង។ ទោះបីយ៉ាងណា លេខាធិការដ្ឋានរមិនអាចមិនប្រជុំពិគ្រោះយោបល់ជាមួយក្រុមបច្ចេកទេសតាមអនុវិស័យបានទេ ពីព្រោះដើម្បីបានជាតុចូលសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ មានភាពច្បាស់លាស់ និងគ្រប់គ្រាន់។

**តារាង៤.៦៖** អ្នកពាក់ព័ន្ធទាំងអស់នៅក្នុងក្រុមបច្ចេកទេស និងក្រុមលេខាធិការដ្ឋានបានចូលរួមប្រជុំពិគ្រោះយោបល់ តាមការអញ្ជើញរបស់ថ្នាក់ដឹកនាំមន្ទីរ។ (គិតជា%)

| ជម្រើស | ប្រធាន/អនុប្រធានមន្ទីរ (n=៩) | ប្រធាន/អនុប្រធានការិ.ផែនការ (n=៩) | ប្រធាន/អនុប្រធាន/មន្ត្រីការិ.ពាក់ព័ន្ធ (n=៣៣) |
|---|---|---|---|
| បានចូលរួមគ្រប់ពេល (១០០%) | ៥៥,៥៦ | ៧៧,៧៨ | ៦៦,៦៧ |
| បានចូលរួមគ្រប់ភាគច្រើន (៥០% ឡើង) | ៤៤,៤៤ | ១១,១១ | ៣០,៣០ |
| បានចូលរួមមួយចំនួន (៥០% ចុះ) | ០,០០ | ១១,១១ | ៣,០៣ |

ដើម្បីឆ្លុះបញ្ចាំងពីការចូលរួមរបស់អ្នកពាក់ព័ន្ធក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ វត្តមានជនបង្គោលនៅក្នុងអង្គប្រជុំតាមការអញ្ជើញពីថ្នាក់ដឹកនាំពិតជាមានសារៈសំខាន់ណាស់ ពីព្រោះដើម្បីផ្តល់ជាតុចូលឱ្យបានគ្រប់ជ្រុងជ្រោយ និងច្បាស់លាស់។ តាមរយៈតារាង៤.៦ បានបង្ហាញថា អ្នកពាក់ព័ន្ធទាំងអស់ ដែលជាក្រុមបច្ចេកទេស និងក្រុមលេខាធិការដ្ឋានបានចូលរួមប្រជុំតាមការអញ្ជើញរបស់ថ្នាក់ដឹកនាំមន្ទីរលើស ៥០% និងភាគតិចបំផុតបានចូលរួមប្រជុំក្រោម ៥០%។ ទិន្នន័យនេះបញ្ជាក់ឱ្យឃើញពីទំនួលខុសត្រូវក្នុងការចូលរួមរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់អ្នកពាក់ព័ន្ធ។

**តារាង៤.៧៖** ការិយាល័យផែនការ និងគ្រប់គ្រងជំនួយបានអញ្ជើញការិយាល័យពាក់ព័ន្ធទាំងអស់ចូលរួមប្រជុំពិគ្រោះយោបល់ និងប្រជុំតាមអនុវិស័យ និងរបាយការណ៍។ (គិតជា%)

| ជម្រើស | ប្រធាន/អនុប្រធានការិ.ផែនការ (n=៩) | ប្រធាន/អនុប្រធាន/មន្ត្រីការិ.ពាក់ព័ន្ធ (n=៣៣) |
|---|---|---|
| បាន១ ទៅ ២ដង | ៣៣,៣៣ | ៤៥,៤៦ |
| បាន៣ ទៅ ៤ដង | ៣៣,៣៣ | ៤២,៤២ |

| | | |
|---|---|---|
| បាន៥ ទៅ ៦ដង | ១១,១១ | ៦,០៦ |
| ច្រើនជាង៦ដង | ២២,២២ | ៦,០៦ |

ផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់រាជធានី ខេត្ត បានរៀបចំឡើងតាម៦អនុវិស័យ ដែលក្រុមលេខាធិការដ្ឋានត្រូវរៀបចំការប្រជុំពិគ្រោះយោបល់តាមអនុវិស័យនីមួយៗ ដើម្បីងាយស្រួលពិភាក្សាប្រមូលទិន្នន័យបានគ្រប់ជ្រុងជ្រោយសម្រាប់ធ្វើការវិភាគ។ ការប្រជុំពិគ្រោះយោបល់បានច្រើនដងកាន់តែល្អប្រសើរ ពីព្រោះ អនុវិស័យនីមួយៗបានចូលរួមកែលម្អទិន្នន័យ ដូចជា វត្ថុបំណងអនុវិស័យ សូចនាករ យុទ្ធសាស្ត្រ សកម្មភាព ឱ្យកាន់តែល្អប្រសើរ។ តាមរយៈតារាង៤.៧ បានបង្ហាញថា ភាគច្រើនការិយាល័យផែនការនិងគ្រប់គ្រងជំនួយបានអញ្ជើញការិយាល័យពាក់ព័ន្ធទាំងអស់ចូលរួមប្រជុំពិគ្រោះយោបល់តាមអនុវិស័យចន្លោះពី ១ ទៅ ៤ដង (៣៣,៣៣%)។ ដូច្នេះ យើងអាចសន្និដ្ឋានបានថា លេខាធិការដ្ឋានពិតជាបានសម្របសម្រួលការងាររៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ បានល្អ។

**តារាងទី៤.៨៖** ការិយាល័យផែនការនិងគ្រប់គ្រងជំនួយបានប្រជុំពិគ្រោះយោបល់ជាមួយការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ សាលារៀន និងអង្គភាព/ស្ថាប័នពាក់ព័ន្ធ ផ្សេងទៀត។ (គិតជា%)

| ជម្រើស | ប្រធាន/អនុប្រធានការិ.ផែនការ (n=៩) |
|---|---|
| បាន១ ទៅ ២ដង | ៤៤,៤៤ |
| មិនបានប្រជុំពិគ្រោះយោបល់ | ៥៥,៥៦ |

ទោះបីជាការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ នៅកម្រិតរាជធានី ខេត្តក៏ដោយ ក៏ត្រូវមានការប្រជុំពិគ្រោះយោបល់ជាមួយការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសាលារៀន ដើម្បីបានធាតុចូលបន្ថែម ក៏ដូចជាបានផ្សព្វផ្សាយដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសាលារៀនឱ្យបានដឹងពីផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣

របស់រាជធានី ខេត្ត ជាពិសេស បង្ហាញពីការរៀបចំផែនការដែលមានលក្ខណៈប្រជាធិបតេយ្យ។ ប្រសិនបើមើលការឆ្លើយរបស់អ្នកចូលរួមផ្តល់ទិន្នន័យ គឺភាគរយបានប្រជុំពិគ្រោះយោបល់ជាមួយការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ សាលារៀន ក្រោម ៥០% ដូច្នេះ រាជធានី ខេត្ត ភាគច្រើនមិនបានប្រជុំពិគ្រោះយោបល់ជាមួយការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសាលារៀននោះទេ នេះបង្ហាញពីកង្វះការចូលរួម ដែលជាមូលហេតុធ្វើឱ្យការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់រាជធានី ខេត្ត មិនមានជាតុចូលគ្រប់ជ្រុងជ្រោយ។ ម្យ៉ាងវិញទៀត រាជធានី ខេត្ត មិនបានអនុវត្តតាមសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា នៅក្នុងដំណើរការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ដែលបានណែនាំថា បន្ទាប់ពីរៀបចំបានសេចក្តីព្រាងលើកទី១ហើយ រាជធានី ខេត្ត ត្រូវប្រជុំពិគ្រោះយោបល់ជាមួយការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសាលារៀន។

**តារាង៤.៩៖** ការិយាល័យពាក់ព័ន្ធបានចូលរួមប្រជុំពិគ្រោះយោបល់ជាមួយការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសាលារៀន។ (គិតជា%)

| ជម្រើស | ប្រធាន/អនុប្រធាន/មន្ត្រីការិ.ពាក់ព័ន្ធ (n=៣៣) |
|---|---|
| បានចូលរួមគ្រប់ពេល (១០០%) | ៦,០៦ |
| បានចូលរួមភាគច្រើន (៥០% ឡើង) | ២៤,២៥ |
| បានចូលរួមមួយចំនួន (៥០% ចុះ) | ៣០,៣០ |
| មិនបានចូលរួម (០%) | ៣៩,៣៩ |

ការប្រជុំពិគ្រោះយោបល់ជាមួយការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសាលារៀនត្រូវមានការចូលរួមពីការិយាល័យពាក់ព័ន្ធ ប្រសិនបើលេខាធិការដ្ឋានមិនបានប្រជុំពិគ្រោះយោបល់ជាមួយការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសាលារៀន នាំឱ្យការិយាល័យពាក់ព័ន្ធមិនបានចូលរួមប្រជុំផងដែរ។ បើផ្អែកលើ តារាង៤.៩ ភាគច្រើនការិយាល័យពាក់ព័ន្ធមិនបានចូលរួមប្រជុំពិគ្រោះយោបល់ជាមួយការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក

ខណ្ឌ និងសាលារៀននោះទេ។ យើងឃើញថា ទិន្នន័យទាំងពីរនេះមានភាពប្រទាក់ក្រឡាគ្នារវាងការិយាល័យផែនការនិងគ្រប់គ្រងជំនួយ និងការិយាល័យពាក់ព័ន្ធ ដែលបានប្រជុំពិគ្រោះយោបល់ជាមួយការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសាលារៀន។

**តារាង៤.១០៖** ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ បានទាន់ពេលវេលាតាមសេចក្តីណែនាំ។ (គិតជា%)

| ជម្រើស | ប្រធាន/អនុប្រធានមន្ទីរ (n=៩) | ប្រធាន/អនុប្រធានការិ.ផែនការ (n=៩) |
|---|---|---|
| ទាន់ពេល | ៧៧,៧៨ | ៦៦,៦៧ |
| យឺតចន្លោះពី១០% - ៣០% | ១១,១១ | ២២,២២ |
| យឺតចន្លោះពី៣០% - ៥០% | ១១,១១ | ១១,១១ |

ទោះបីមន្ទីរអប់រំ យុវជន និងកីឡាមានការងារច្រើន ក៏ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ជាការងារអាទិភាព។ តាមរយៈតារាង៤.១០ បានបង្ហាញថា ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ របស់រាជធានី ខេត្ត បានទាន់ពេលវេលាស្ទើរតែ ១០០% ដូច្នេះរាជធានី ខេត្ត បានខិតខំប្រឹងប្រែងរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ នេះ តាមក្របខណ្ឌពេលវេលានៅសេក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា។

### ៤.២.៣ ដំណើរការរៀបចំ

**តារាង៤.១១៖** លំដាប់លំដោយនៃដំណើរការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣។ (គិតជា%)

| | ១.ត្រូវខ្លឹមសារ និងលំដាប់លំដោយ | ២.ត្រូវខ្លឹមសារ ខុសលំដាប់លំដោយ | ៣.មិនមានមតិយោបល់ | ៤.ខុសខ្លឹមសារ ត្រូវលំដាប់លំដោយ | ៥.ខុសខ្លឹមសារមួយចំនួន ខុសលំដាប់លំដោយ |
|---|---|---|---|---|---|

| | | | | | |
|---|---|---|---|---|---|
| ប្រធាន/អនុប្រធានការិ.ផែនការ (n=៩) | ០,០០ | ០,០០ | ០,០០ | ០,០០ | ១០០ |
| ប្រធាន/អនុប្រធាន/មន្ត្រីការិ.ពាក់ព័ន្ធ (n=៣៣) | ០,០០ | ០,០០ | ០,០០ | ០,០០ | ១០០ |

នៅក្នុងសេចក្តីណែនាំ បានរៀបរាប់ពីដំណើរការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ របស់រាជធានី ខេត្តតាមលំដាប់លំដោយដូចតទៅ៖ (១) ការបង្កើតក្រុមការងារ (២) ការពិនិត្យនិងពិភាក្សាកំណត់គោលនយោបាយអាទិភាពនិងសូចនាករផលសម្រេច (៣) ការកំណត់ចក្ខុវិស័យ និងវត្ថុបំណងគោលនយោបាយ (៤) ការរៀបចំផែនការ និងការប្រជុំតាមអនុវិស័យ (៥) ការរៀបចំតម្រូវការថវិកា (៦) ការរៀបចំសេចក្តីព្រាងលើកទី១ (៧) ការពិគ្រោះយោបល់ជាមួយការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសាលារៀន (៨) ការរៀបចំសេចក្តីព្រាងចុងក្រោយ (៩) ការអនុម័តជាផ្លូវការ។

បើយោងតាមសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ការឆ្លើយរបស់ការិយាល័យផែនការនិងគ្រប់គ្រងជំនួយ និងការិយាល័យពាក់ព័ន្ធត្រូវតាមខ្លឹមសារមួយចំនួន និងខុសលំដាប់លំដោយ។ តាមរយៈតារាង៤.១១ បានបង្ហាញថា ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់រាជធានី ខេត្ត ទៅតាមភាពជាក់ស្តែងរបស់រាជធានី ខេត្តនីមួយៗ ដោយមិនបានអនុវត្តតាមលំដាប់លំដោយសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា នោះទេ ដូច្នេះ នាំឱ្យការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់រាជធានី ខេត្ត មិនមានភាពប្រទាក់ក្រឡាគ្នាពីមួយដំណាក់កាលទៅមួយដំណាក់កាល និងមានភាពច្របូកច្របល់។

**តារាង៤.១២៖** លំដាប់លំដោយនៃដំណើរការរៀបចំថវិកានៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣។ (គិតជា%)

| | ១.ត្រូវខ្លឹមសារ និង | ២.ត្រូវខ្លឹមសារ ខុស | ៣.មិនមានមតិយោបល់ | ៤.ខុសខ្លឹមសារ ត្រូវ | ៥.ខុសខ្លឹមសារមួយ |
|---|---|---|---|---|---|

| | លំដាប់ លំដោយ | លំដាប់ លំដោយ | | លំដាប់ លំដោយ | ចំនួន ខុស លំដាប់ លំដោយ |
|---|---|---|---|---|---|
| ប្រធាន/អនុប្រធានការិ.ផែនការ (n=៩) | 0,00 | 0,00 | 0,00 | 0,00 | ១00 |
| ប្រធាន/អនុប្រធាន/មន្ត្រីការិ.ពាក់ព័ន្ធ (n=៣៣) | 0,00 | 0,00 | 0,00 | 0,00 | ១00 |

តាមសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា តម្រូវឱ្យរាជធានី ខេត្ត ព្យាករណ៍តម្រូវការហិរញ្ញវត្ថុពីឆ្នាំ ២០១៩ ដល់ ២០២៣ ដោយរួមបញ្ចូលទាំងសកម្មភាពគាំទ្រដំណើរការអង្គភាព សាលារៀន និងសកម្មភាពអភិវឌ្ឍ ការព្យាករណ៍រួមទាំងថវិកាចរន្ត និងថវិកាមូលធន។ ការព្យាករណ៍ត្រូវឆ្លុះបញ្ចាំងពីការបែងចែកការទទួលខុសត្រូវរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលត្រូវបន្សីទៅនឹងក្របខណ្ឌថវិការបស់សាលារៀន តាមរាជធានី ខេត្តផងដែរ។ ម៉ូលដែល CANPRO ត្រូវធ្វើបច្ចុប្បន្នភាព ដើម្បីជាជំនួយក្នុងការព្យាករណ៍ និងជាម៉ូដែល ដែលនឹងប្រើប្រាស់ដូចគ្នាក្នុងចំណោមរាជធានី ខេត្ត ទាំងអស់។ តាមទិន្នន័យបង្ហាញថា រាជធានី ខេត្តបានរៀបចំថវិកាទៅតាមរាជធានី ខេត្តរៀងៗខ្លួន ដោយមិនគិតពីលំដាប់លំដោយពីព្រោះវាពិបាកសម្រាប់រាជធានី ខេត្ត អនុវត្តតាមសេចក្តីណែនាំនៅពេលមិនទាន់ដឹងពីចំនួនថវិកាពិតប្រាកដ ពិសេសថវិកាដៃគូអភិវឌ្ឍ និងអង្គការមួយចំនួន ដែលពិបាកធ្វើការព្យាករណ៍ពីតម្រូវការថវិកា។ ដូច្នេះ រាជធានី ខេត្ត បានរៀបចំថវិកាបទបែនទៅតាមភាពជាក់ស្តែងរៀងៗខ្លួនតាមបទពិសេធរបស់ខ្លួន ដែលការិយាល័យគណនេយ្យជាអ្នកសម្របសម្រួលធ្វើយ៉ាងណាឱ្យដំណើរការរៀបចំថវិកានេះ មានភាពងាយស្រួល និងមិនលម្អៀងខ្លាំង។

## ៤.៣ វាយតម្លៃផែនការរាជធានីខេត្ត ធៀបនឹងស្តង់ដាផែនការថ្នាក់ជាតិ

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់រាជធានី ខេត្ត បានរៀបចំឡើង ដោយមាន ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់ថ្នាក់ជាតិជាគោល ដែលរាជធានី ខេត្ត ត្រូវ

រៀបចំឱ្យមានសង្គតិភាពជាមួយថ្នាក់ជាតិ ទើបសម្រេចចក្ខុវិស័យ និងគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ជាតុសំខាន់ៗដែលត្រូវប្រៀបធៀបជាមួយថ្នាក់ជាតិរួមមាន (១) សូចនាករស្នូល (២) វត្ថុបំណងអនុវិស័យ (៣) សូចនាករតាមអនុវស័យ (៤) ចំណុចដៅ (៥) យុទ្ធសាស្ត្រ និង(៦) សកម្មភាព។

តាមរយៈការពិនិត្យមើលផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់រាជធានី ខេត្ត បានបង្ហាញថា ការកំណត់សូចនាករស្នូលរបស់រាជធានី ខេត្ត មានសង្គតិភាពជាមួយថ្នាក់ជាតិ ក៏ដូចជាសមស្របតាមបរិបទរបស់រាជធានី ខេត្ត ដោយសូចនាកររបស់រាជធានី ខេត្តមួយចំនួនដូចនឹងថ្នាក់ជាតិ និងមួយចំនួនមិនដូចនឹងថ្នាក់ជាតិ ប៉ុន្តែ រាជធានី ខេត្តបានកែសម្រួល ដើម្បីឱ្យមានទិន្នន័យសម្រាប់វាស់វែង។ ការកំណត់វត្ថុបំណងអនុវិស័យរបស់ថ្នាក់ជាតិមាន៣ ដែល២គាំទ្រឱ្យគោលនយោបាយទី១ និង១គាំឱ្យគោលនយោបាយទី២ ក្នុងនោះរាជធានី ខេត្ត ក៏បានកំណត់វត្ថុបំណងអនុវិស័យនេះ មាន៣ ផងដែរ។ ម្យ៉ាងវិញទៀត ការកំណត់សូចនាករតាមអនុវិស័យ និងសូចនាករស្នូលរបស់រាជធានី ខេត្ត មិនសូវខុសពីថ្នាក់ជាតិប៉ុន្មានដែរ គឺរាជធានី ខេត្ត បានកំណត់តាមថ្នាក់ជាតិ និងទៅតាមអ្វីដែលរាជធានី ខេត្តមាន ចំណែកឯការកំណត់ចំណុចដៅវិញ រាជធានី ខេត្ត បានកំណត់ដោយផ្អែកលើទិន្នន័យឆ្នាំគោល ២០១៧-២០១៨ និងបានកំណត់ចំណុចដៅសម្រាប់ឆ្នាំ២០២២-២០២៣ ដោយមានការគណនាតាមរូបមន្តកំណើនថេរនៅក្នុង CANPRO។ យុទ្ធសាស្ត្រ និងសកម្មភាពដែលរាជធានី ខេត្តប្រើមានភាពខុសៗគ្នាបន្តិចបន្តួចទៅតាមស្ថានភាពរបស់រាជធានី ខេត្ត នីមួយៗ ប៉ុន្តែមិនឃ្លាតឆ្ងាយពីថ្នាក់ជាតិប៉ុន្មានទេ។ តាមការពិនិត្យឃើញ រាជធានី ខេត្តបានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ទៅតាមទម្រង់របស់ថ្នាក់ជាតិ ដោយមានការកែសម្រួលឱ្យសមស្របតាមរាជធានី ខេត្តរបស់ខ្លួន។ ម្យ៉ាងវិញទៀត បើប្រៀបធៀប ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់រាជធានី ខេត្ត ទាំង៩ បានបង្ហាញថា ផែនការទាំងនេះ មានលក្ខណៈប្រហាក់ប្រហែលគ្នាច្រើន ដូចនេះ យើងអាចសន្និដ្ឋានបានថា រាជធានី ខេត្ត បានមើលគំរូគ្នាទៅវិញទៅមក។ សរុបមក យើងអាចវាយតម្លៃការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់រាជធានី ខេត្ត បានថា មានលក្ខណៈល្អប្រសើរច្រើន បើប្រៀបធៀប

ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំកន្លងមក ប៉ុន្តែនៅមានចំណុចមួយចំនួនត្រូវកែលម្អ ដើម្បីឱ្យផែនការនេះមានគុណភាពកាន់តែល្អប្រសើរ និងអាចអនុវត្តបានសម្រេចតាមគោលដៅដែលបានកំណត់។

## ៤.៤ ការពង្រឹងសមត្ថភាពបុគ្គលិក និងការគាំទ្រ

**តារាង៤.១៣៖** ក្រុមបង្គោលតាមអនុវិស័យនីមួយៗបានទទួលការបណ្តុះបណ្តាល និងការណែនាំស្តីពីផែនការអប់រំ។ (គិតជា%)

| ជម្រើស | ប្រធាន/អនុប្រធានមន្ទីរ (n=៩) | ប្រធាន/អនុប្រធានការិ.ផែនការ (n=៩) | ប្រធាន/អនុប្រធាន/មន្ត្រីការិ.ពាក់ព័ន្ធ (n=៣៣) |
|---|---|---|---|
| បានទទួលការបណ្តុះបណ្តាល និងការណែនាំពីនាយកដ្ឋានផែនការ អង្គភាព/ស្ថាប័នផ្សេង | ៤៤,៤៥ | ៦៦,៦៧ | ២៤,២៥ |
| បានទទួលការបណ្តុះបណ្តាល និងការណែនាំពីមន្ត្រីជំនាញផែនការរបស់មន្ទីរអប់រំ យុវជន និងកីឡា | ៤៤,៤៤ | ១១,១១ | ៤៥,៤៥ |
| បានទទួលឯកសារពាក់ព័ន្ធនានាអំពីការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំពីការិយាល័យផែនការនិងគ្រប់គ្រងជំនួយ ឬការិយាល័យផ្សេង ឬថ្នាក់ដឹកនាំមន្ទីរ | ១១,១១ | ២២,២២ | ២១,២១ |
| មិនបានទទួលការបណ្តុះបណ្តាល ឬការណែនាំ | ០,០០ | ០,០០ | ៩,០៩ |

ការពង្រឹងសមត្ថភាពជាកត្តាសំខាន់ ដែលមិនអាចខ្វះបាន ដើម្បីរាជធានី ខេត្ត មានសមត្ថភាពរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំប្រកបដោយគុណភាព និងមានភាពជាម្ចាស់។ តាមរយៈតារាង៤.១៣ បានបង្ហាញថា ភាគច្រើនថ្នាក់ដឹកនាំមន្ទីរ និងការិយាល័យផែនការនិងគ្រប់គ្រងជំនួយបានទទួលការបណ្តុះបណ្តាលពីនាយកដ្ឋានផែនការ ផ្ទុយទៅវិញការិយាល័យពាក់ព័ន្ធភាគច្រើនបានទទួលការបណ្តុះបណ្តាលពីមន្ទីរអប់រំ យុវជន និងកីឡា។ ទោះបីយ៉ាងណា មន្ត្រីបង្គោលក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំតាមអនុវិស័យ និងការិយល័យគាំទ្រសុទ្ធតែបានទទួលការបណ្តុះបណ្តាលពីការរៀបចំផែនការ

ភាគតិចណាស់ដែលមិនបានទទួលការបណ្តុះបណ្តាល។ ដូច្នេះ រាជធានី ខេត្តមានសមត្ថភាពក្នុងរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ។

**តារាង៤.១៤៖** នាយកដ្ឋានផែនការបានជួយសម្របសម្រួល និងគាំទ្របច្ចេកទេសដល់ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣។ (គិតជា%)

| ជម្រើស | ប្រធាន/អនុប្រធានមន្ទីរ (n=៩) | ប្រធាន/អនុប្រធានការិ.ផែនការ (n=៩) |
|---|---|---|
| បានចុះជួយគាំទ្របច្ចេកទេសក្នុងអំឡុងពេលរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ | ២២,២២ | ៣៣,៣៣ |
| បានរៀបចំសិក្ខាសាលាពិនិត្យវឌ្ឍនភាព និងបញ្ហាប្រឈមនៃការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ជាមួយរាជធានីខេត្ត | ៤៤,៤៥ | ៣៣,៣៣ |
| បានពិនិត្យសេចក្តីព្រាងផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ ដែលបានផ្ញើមកពីមន្ទីរ និងផ្តល់យោបល់កែលម្អ | ២២,២២ | ២២,២២ |
| បានចូលរួមប្រជុំពិគ្រោះយោបល់ជាមួយក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំនៅមន្ទីរ | ១១,១១ | ១១,១១ |

ទោះបីជាមន្ទីរមានសមត្ថភាពរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ក៏នៅតែត្រូវការការគាំទ្របច្ចេកទេស ដើម្បីឱ្យដំណើររៀបចំផែនយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់រាជធានី ខេត្តមានភាពរលូន ដូចទិន្នន័យនៅក្នុងតារាង៤.១៤ បានបង្ហាញថា ថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡាមាន ៤៤,៤៥% និងការិយាល័យផែនការនិងគ្រប់គ្រងជំនួយ មាន ៣៣,៣៣% បានឆ្លើយថា នាយកដ្ឋានផែនការបានជួយសម្របសម្រួល និងគាំទ្របច្ចេកទេសដល់ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ តាមរយៈការរៀបចំសិក្ខាសាលាពិនិត្យវឌ្ឍនភាព និងបញ្ហាប្រឈមនៃការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ ជាមួយរាជធានី ខេត្ត ក្នុងនោះការចុះជួយគាំទ្របច្ចេកទេសក្នុង

អំឡុងពេលរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ មានភាគតិច និងការចូលរួមប្រជុំពិគ្រោះយោបល់ជាមួយក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំនៅមន្ទីរអប់រំ យុវជន និងកីឡា មានភាគតិចបំផុត។ នេះបញ្ជាក់ថា នាយកដ្ឋានផែនបានជួយសម្របសម្រួល និងគាំទ្របច្ចេកទេសដល់ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ តាមមួយរូបភាពប៉ុណ្ណោះ គឺការរៀបចំសិក្ខាសាលា។

**តារាង៤.១៥៖** ការិយាល័យផែនការ និងគ្រប់គ្រងជំនួយបានជួយគាំទ្របច្ចេកទេសដល់ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣។ (គិតជា%)

| ជម្រើស | ប្រធាន/អនុប្រធាន/មន្ត្រីការិ.ពាក់ព័ន្ធ (n=៣៣) |
|---|---|
| ប្រជុំណែនាំ | ៧៨,៧៩ |
| ជួយគាំទ្រនៅពេលត្រូវការ | ២១,២១ |

ជាធម្មតាការិយាល័យផែនការនិងគ្រប់គ្រងជំនួយ បានទទួលការបណ្តុះបណ្តាលស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំពីនាយកដ្ឋានផែនការ បន្ទាប់មកការិយាល័យផែនការ និងគ្រប់គ្រងជំនួយបានជួយគាំទ្របច្ចេកទេសដល់ការិយាល័យពាក់ព័ន្ធក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ តាមរូបភាពផ្សេងៗ ដូចទិន្នន័យក្នុងតារាង៤.១៥ បានបង្ហាញថា ភាគច្រើនការិយាល័យផែនការនិងគ្រប់គ្រងជំនួយ បានប្រជុំណែនាំដល់ការិយាល័យពាក់ព័ន្ធក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ មាន ៧៨,៧៩% និងជួយគាំទ្រនៅពេលការិយាល័យពាក់ព័ន្ធត្រូវការ មាន ២១,២១%។ តាមរយៈទិន្នន័យ យើងអាចសន្និដ្ឋានបានថា ការិយាល័យផែនការនិងគ្រប់គ្រងជំនួយបានជួយសម្របសម្រួល និងគាំទ្របច្ចេកទេសដល់ការិយាល័យពាក់ព័ន្ធ ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣។

**តារាង៤.១៦៖** ក្រុមបង្គោលតាមអនុវិស័យនីមួយៗបានទទួលការបណ្តុះបណ្តាល និងការណែនាំស្តីពីផែនការអប់រំ។ (គិតជា%)

| ជម្រើស | ប្រធាន/អនុប្រធានមន្ទីរ (n=៩) | ប្រធាន/អនុប្រធាន/មន្ត្រីការិ.ពាក់ព័ន្ធ (n=៣៣) |
|---|---|---|
| បានទទួលការបណ្តុះបណ្តាលតាមរយៈនាយកដ្ឋានផែនការ ឬអង្គភាព/ស្ថាប័នផ្សេង | ៥៥,៥៦ | ២៤,២៤ |
| បានទទួលការបណ្តុះបណ្តាល ឬការណែនាំពីមន្ត្រីជំនាញផែនការរបស់មន្ទីរអប់រំ យុវជន និងកីឡា | ៤៤,៤៤ | ៤៥,៤៦ |
| បានទទួលឯកសារពាក់ព័ន្ធនានាអំពីការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំពីការិយាល័យផែនការនិងគ្រប់គ្រងជំនួយ ឬការិយាល័យផ្សេង ឬថ្នាក់ដឹកនាំមន្ទីរ | 0,00 | ២១,២១ |
| មិនបានទទួលការបណ្តុះបណ្តាល ឬការណែនាំ | 0,00 | ៩,០៩ |

ដើម្បីឱ្យការងារមួយដំណើរការទៅល្អ ត្រូវមានជនបង្គោលទទួលបន្ទុកក្នុងការផ្តល់ជាតុចូលផ្សេងៗតាមតម្រូវការ និងទទួលការបណ្តុះបណ្តាលពីការងារចំពោះមុខដូចជាការងាររៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ មានដំណើរការល្អត្រូវមានជនបង្គោលទទួលខុសត្រូវតាមអនុវិស័យនីមួយៗ និងត្រូវបានទទួលការបណ្តុះបណ្តាលពីការងារនោះ។ តាមរយៈតារាង៤.១៦ បានបង្ហាញថា ថ្នាក់ដឹកនាំមន្ទីរភាគច្រើន (៥៥,៥៦%) បានឆ្លើយថា ក្រុមបង្គោលតាមអនុវិស័យនីមួយៗបានទទួលការបណ្តុះបណ្តាលនិងការណែនាំស្តីពីផែនការអប់រំពីនាយកដ្ឋានផែនការ និងការិយាល័យពាក់ព័ន្ធភាគច្រើន (៤៥,៤៦%) បានឆ្លើយថា បានទទួលការបណ្តុះបណ្តាល ឬការណែនាំពីមន្ត្រីជំនាញផែនការរបស់មន្ទីរអប់រំ យុវជន និងកីឡា ក្នុងនោះក៏មានការិយាល័យពាក់ព័ន្ធមួយចំនួន (៩ ,០៩%) មិនបានទទួលការបណ្តុះបណ្តាល ឬណែនាំ។ ដូច្នេះ យើងអាចសន្និដ្ឋានបានថា ក្រុមបង្គោលបានទទួលការបណ្តុះបណ្តាលស្តីពីផែនការអប់រំបានគ្រប់ៗគ្នា ប៉ុន្តែនៅមានតិចតួចប៉ុណ្ណោះ ដែលមិនបានទទួលការបណ្តុះបណ្តាលសម្រាប់មន្ត្រីថ្មី។

## ៤.៥ បញ្ហាប្រឈម និងដំណោះស្រាយ

### ៤.៥.១ បញ្ហាប្រឈម

**តារាង៤.១៧៖** បញ្ហាប្រឈមអ្វីខ្លះក្នុងដំណើរការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣។ (គិតជា%)

| បញ្ហាប្រឈម | ប្រធាន/អនុប្រធានមន្ទីរ (n=៩) | ប្រធាន/អនុប្រធានការិ.ផែនការ (n=៩) | ប្រធាន/អនុប្រធាន/មន្ត្រីការិ.ពាក់ព័ន្ធ (n=៣៣) |
|---|---|---|---|
| សមត្ថភាព | ៥៥,៥៦ | ១០០ | ៦០,៦០ |
| បច្ចេកទេស និងការសម្របសម្រួល | ១១,១១ | ២២,២២ | ១២,១២ |
| ការចូលរួមពីអ្នកពាក់ព័ន្ធ | ១១,១១ | ២២,២២ | ៣,០៣ |
| ការផ្លាស់ប្តូរមន្ត្រី | ១១,១១ | ០,០០ | ០,០០ |
| ទិន្នន័យ | ១១,១១ | ២២,២២ | ៩,០៩ |
| ពេលវេលា | ១១,១១ | ៤៤,៤៤ | ៦,០៦ |
| បន្ទុកការងារច្រើន | ១១,១១ | ១១,១១ | ០,០០ |
| ថវិកា | ០,០០ | ២២,២ | ២៧,២៧ |
| ខ្វះលិខិតបទដ្ឋានគតិយុត្តគាំទ្រ | ០,០០ | ០,០០ | ៣,០៣ |

រាជធានី ខេត្តបានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ លើកទី៣នេះបានចប់សព្វគ្រប់ ដែលជាវឌ្ឍនភាពមួយសម្រាប់រាជធានី ខេត្ត។ ទទ្ទឹមនឹងលទ្ធផលល្អនេះ រាជធានី ខេត្ត នៅមានបញ្ហាប្រឈមជាច្រើននៅក្នុងដំណើរការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ នេះ ដូចដែលទិន្នន័យនៅក្នុងតារាង៤.១៧ បានបង្ហាញថា មានបញ្ហាប្រឈមសំខាន់ៗចំនួន ៩ ក្នុងនោះបញ្ហាប្រឈមដែលបានលើកឡើងភាគច្រើន គឺសមត្ថភាពមន្ត្រីទទួលបន្ទុកផែនការនៅមានកម្រិត ក្នុងចំណោមថ្នាក់

ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡា ៩នាក់ បានលើកឡើងពីបញ្ហាប្រឈមពាក់ព័ន្ធនឹងសមត្ថភាពនេះ ៥ នាក់ស្មើនឹង ៥៥,៥៦% ការិយាល័យផែនការនិងគ្រប់គ្រងជំនួយ ទាំង៩នាក់ ស្មើនឹង ១០០% និងការិយាល័យពាក់ព័ន្ធ ៣៣នាក់ បានលើកឡើង២០នាក់ ស្មើនឹង ៦០,៦០% ក្រៅពីបញ្ហាប្រឈមពាក់ព័ន្ធនឹងសមត្ថភាព នៅមានបញ្ហាប្រឈមជាច្រើនទៀត ដូចជាការចូលរួមពីអ្នកពាក់ព័ន្ធមិនបានពេញលេញ ខ្វះទិន្នន័យ រយៈពេលខ្លី មន្ត្រីទទួលបន្ទុកផែនការថ្មីជាដើម។ តាមរយៈតារាង៤.១៦ យើងអាចសន្និដ្ឋានបានថា ទោះបីមន្ទីរបាទទួលការបណ្ដុះបណ្ដាលស្ដីពីផែនការអប់រំក៏ដោយ ក៏មន្ត្រីទទួលបន្ទុលផែនការនៅរាជធានី ខេត្ត មិនទាន់យល់ច្បាស់ពីការរៀបចំផែនការយុទ្ធសាស្ត្រនៅឡើយ។

### ៤.៥.២ ដំណោះស្រាយ

**តារាង ៤.១៨៖** ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំមានប្រសិទ្ធភាព។ (គិតជា%)

| យោបល់ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំឱ្យមានប្រសិទ្ធភាព | ប្រធាន/អនុប្រធានមន្ទីរ (n=៩) | ប្រធាន/អនុប្រធានការិ.ផែនការ (n=៩) | ប្រធាន/អនុប្រធាន/មន្ត្រីការិ.ពាក់ព័ន្ធ (n=៣៣) |
|---|---|---|---|
| មានលិខិតបទដ្ឋានគតិយុទ្ធគាំទ្រ និងគោលនយោបាយ | ១១,១១ | ០,០០ | ៦,០៦ |
| ការបណ្ដុះបណ្ដាល ឬការបង្វឹក ឬការបំប៉នសមត្ថភាព | ៦៦,៦៧ | ១០០ | ៤៨,៤៨ |
| ការគាំទ្រធនធាន (មនុស្ស សម្ភារថវិកា) | ១១,១១ | ២២,២២ | ៣,០៣ |
| ការគាំទ្របច្ចេកទេស | ២២,២២ | ១១,១១ | ០,០០ |
| ការចូលរួម | ១១,១១ | ៤៤,៤៤ | ៦,០៦ |
| ការលើកទឹកចិត្ត | ១១,១១ | ៣៣,៣៣ | ០,០០ |
| ការផ្សារភ្ជាប់ផែនការនឹងថវិកាផែនការផ្សេងៗ និងដឹងពីតម្រូវការ | ២២,២២ | ១១,១១ | ៦,០៦ |

| | | | |
|---|---|---|---|
| ឱ្យតម្លៃផែនការ | ១១,១១ | 0,00 | ៣,0៣ |
| ក្របខណ្ឌពេលវេលា | 0,00 | ១១,១១ | ៣,0៣ |
| ការផ្សព្វផ្សាយ | 0,00 | ១១,១១ | ៣,0៣ |
| មានទិន្នន័យគ្រប់គ្រាន់ | 0,00 | 0,00 | ៦,0៦ |
| កំណត់ចំណុចដៅ សូចនាករ យុទ្ធសាស្ត្រ និងសកម្មភាពឱ្យបានច្បាស់លាស់ | 0,00 | 0,00 | ១២,១២ |
| អនុវត្ត ពិនិត្យតាមដាន និងវាយតម្លៃផែនការ | 0,00 | ១១,១១ | ៣,0៣ |

មន្ទីរអប់រំ យុវជន និងកីឡា បានផ្តល់យោលបល់ពីការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំឱ្យមានប្រសិទ្ធភាពមានចំណុចសំខាន់ៗចំនួយ១៣ចំណុច ដែលក្នុងនោះ អ្នកចូលរួមផ្តល់មតិភាគច្រើនបានលើកឡើងពីការបំប៉នសមត្ថភាពមន្ត្រីទទួលបន្ទុកផែនការ ដែលក្នុងចំណោមថ្នាក់ដឹកនាំមន្ទីរ៩នាក់ មាន៦នាក់ ស្មើនឹង ៦៦,៦៧% ការិយាល័យផែនការ និងគ្រប់គ្រងជំនួយទាំង៩នាក់ ស្មើនឹង ១00% និងការិយាល័យពាក់ព័ន្ធ ១៦នាក់ ក្នុងចំណោម ៣៣នាក់ ស្មើនឹង ៤៨,៤៨% បានផ្តល់មតិលើការបំប៉នសមត្ថភាព ក្នុងនោះក៏មានចំណុចជាច្រើនទៀត ដែលជួយឱ្យការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំមានប្រសិទ្ធភាពដូចជាការចូលរួមពីអ្នកពាក់ព័ន្ធ ការប្រមូលទិន្នន័យ ការវិភាគស្ថានភាព ធនធានគាំទ្រ។ល។ តាមរយៈតារាង៤.១៨ បានបង្ហាញថា សមត្ថភាពជាចំណុចសំខាន់ ដែលត្រូវយកចិត្តទុកដាក់ ដើម្បីឱ្យមន្ត្រីទទួលបន្ទុកការងារផែនការនៅតាមថ្នាក់រាជធានី ខេត្ត អាចរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំប្រកបដោយប្រសិទ្ធភាព។

# ជំពូក៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១ សេចក្តីសន្និដ្ឋាន

កំណែទម្រង់ប្រព័ន្ធអប់រំ តាមរយៈការពង្រឹងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ផែនការយុទ្ធសាស្ត្រថវិកា និងផែនការប្រតិបត្តិប្រចាំឆ្នាំនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ពិតជាមានសារៈសំខាន់ក្នុងការអភិវឌ្ឍវិស័យអប់រំ។ តាមរយៈការស្រាវជ្រាវបានឆ្លុះបញ្ចាំងពីការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់រាជធានី ខេត្ត មានវឌ្ឍនភាពគួរឱ្យគាត់សម្គាល់ ដោយសារ រាជធានី ខេត្ត បានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ មានដំណើរការល្អ ដោយបានអនុវត្តតាមសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា និងបានរៀបចំចប់សព្វគ្រប់ទាំង២៥ រាជធានី ខេត្ត ប៉ុន្តែការរៀបចំផែនការសាស្ត្រវិស័យអប់រំនេះ មិនទាន់បានល្អប្រសើរនៅឡើយ ក្នុងការឆ្លើយតបទៅនឹងផែនការអភិវឌ្ឍន៍របស់រាជានី ខេត្ត ដោយសារសមត្ថភាពអ្នករៀបចំផែនការនៅមានកម្រិត ខ្វះការប្រជុំពិគ្រោះយោបល់ជាមួយការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសាលារៀន និងការគាំទ្រពីថ្នាក់ជាតិ។ ទោះបីជាអ្នកចូលរួមរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ មានបទពិសេធក្នុងការងារផែនការភាគច្រើនលើសពី៥ឆ្នាំក៏ដោយ ក៏ការអភិវឌ្ឍសមត្ថភាពត្រូវធ្វើជាប្រចាំដើម្បីឆ្លើយតបទៅនឹងការវិវឌ្ឍន៍របស់សង្គម និងបច្ចេកវិទ្យា។ ប្រសិនបើយើងពិនិត្យលើផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់រាជធានី ខេត្ត យើងឃើញថា ផែនការទាំងនេះ មានលក្ខណៈប្រហាក់ប្រហែលគ្នា ដូច្នេះតាមការសន្និដ្ឋាន រាជធានី ខេត្ត អាចរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ យកតាមលំនាំគ្នាទៅវិញទៅមក ដោយមានការកែសម្រួលឱ្យសមស្របតាមបរិបទរាជធានី ខេត្តរៀងៗខ្លួន។ សរុបមក ការរៀបចំផែនការយុទ្ធសាស្ត្រ វិស័យអប់រំ ២០១៩-២០២៣ របស់រាជធានី ខេត្ត បានល្អ ដោយមានខ្លឹមសារគ្រប់គ្រាន់ អាចអនុវត្តបាន ប៉ុន្តែការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់រាជធានី ខេត្ត មិនទាន់មានគុណភាពល្អប្រសើរ ដោយសារតែខ្វះការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ និងការប្រជុំពិគ្រោះយោបល់ពីការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសាលារៀន។ ដូច្នេះ រាជធានី ខេត្ត ត្រូវការពង្រឹងការរៀបចំផែនការយុទ្ធសាស្ត្រ

វិស័យអប់រំបន្ថែមទៀត ដើម្បីឱ្យផែនការយុទ្ធសាស្ត្រវិស័យអប់រំក្រោយៗទៀតកាន់តែមានគុណភាពល្អប្រសើរ។

## ៥.២ សំណូមពរ

យោងតាមការស្រាវជ្រាវ៖

- ✓ ក្រសួង និងមន្ទីរអប់រំ យុវជន និងកីឡា គួរតែផ្សព្វផ្សាយក្របខណ្ឌនៃការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំឱ្យបានទូលំទូលាយដល់អ្នកពាក់ព័ន្ធ
- ✓ ក្រសួង និងមន្ទីរអប់រំ យុវជន និងកីឡា គួរតែផ្តល់ការបណ្តុះបណ្តាលស្តីពីផែនការយុទ្ធសាស្ត្រវិស័យអប់រំ ដល់គ្រប់ការិយាល័យពាក់ព័ន្ធ
- ✓ ក្រសួងអប់រំ យុវជន និងកីឡា គួរតែជួយគាំបច្ចេកទេសតាមគ្រប់រូបភាពដល់រាជធានី ខេត្ត ក្នុងអំឡុងពេលរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ
- ✓ មន្ទីរអប់រំ យុវជន និងកីឡា គួរតែប្រជុំពិគ្រោះយោបល់លើផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់មន្ទីរជាមួយការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋាលក្រុង ស្រុក ខណ្ឌ និងសាលារៀន
- ✓ មន្ទីរគួរតែរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំតាមបរិបទរបស់រាជធានី ខេត្ត រៀងៗខ្លួនជៀសវាងការចម្លងគ្នា។

## សំណូមពរសម្រាប់អ្នកសិក្សាក្រោយ

- ✓ សូមធ្វើការសិក្សាស្រាវជ្រាវពីការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ របស់ថ្នាក់រាជធានី ខេត្ត។

# ឯកសារយោង


A. Misztal. .(2013) Determinants of success the quality management systems implementation. *Quality planning in various sectors companies*, .779

Agnieszka Misztal. .(2013) Determinants of success the quality management systems implementation. *Quality planning in various sectors companies*, .779

ESP.(2023-2019)

ESP.(2023-2019)

G. C. a CHANG. .(2008) *Strategic Planning in Education: Some Concepts and Methods.* paris: IIEP.

G. C. b CHANG. .(2008) *Strategic Planning in Education: Some Concepts and Methods.* Paris: IIEP.

G. C. CHANG. .(2008) *Strategic Planning in Education: Some Concepts and Methods.* paris: IIEP.

G. Chol CHANG. .(2011) *Strategic Planning Concept and rationale.* Paris: IIEP.

Gwang-Chol CHANG. .(2008) *Strategic Planning in Education: Some Concepts and Methods.* Paris: IIEP.

Hite, S. J. & De Grauwe, A. a. .(2009) *Capacity Development in Educational Planning and Management: Learning from successes and failures.* Paris: IIEP.

Hite, S. J. & De Grauwe, A. b. .(2009) *Capacity developmemt in educational planning and management: learning from successes and failures.* Paris: IIEP.

I. H. Gonzalez Escobar. .(2019) New Trends and Issues Proceedings on Humanities and Social Sciences. *School improvement plans, a tool to improve the quality of education,* (1)*6*, .441

I.H. Gonzalez Escobar. .(2019) New Trends and Issues Proceedings on Humanities and Social Sciences. *School improvement plans, a tool to improve the quality of education,* (1)*6*, .441

IIEP. .(2010) *Strategic planning Organizational arrangements.* Paris: IIEP.

IIEP. .(2010) *Strategic planning: Concept and rationale.* Paris: IIEP.

IIEP. .(2010) *Strategic planning: Concept and rationale.* Paris: IIEP.

IIEP. .(2010) *Strategic Planning: Concept and rationale.* Paris: IIEP.

IIEP-UNESCO. .(2015) *Guidelines fo Education Sector Plan Preparation.* Paris: IIEP-UNESCO.

MoEYS. .(2019) *Education Strategic Plan .2023-2019* Phnom Penh: MoEYS.

Onn, S., & Hyojin, K. .(2019) Challenges to provincial education Strategic Plan Preparation in Cambodia. *Education Research Council,* (1)*3*, .111-107

Onn, S., & Hyojin, K. .(2019) Challenges to Provincial Education Strategic Plan Preparation in Cambodia. *Education Research Council,* (1)*3*, .98

